ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាល

# គោលនយោបាយជាតិលើវិស័យធនធានទឹក

# នៅក្នុង

# ព្រះរាជាណាចក្រកម្ពុជា

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនា

ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០០៤

រៀបចំដោយក្រសួងធនធានទឹក និងឧតុនិយម

# មាតិកា


| | ទំព័រ |
|---|---|
| ១-សេចក្តីផ្តើម | ១ |
| ២-ចក្ខុវិស័យទឹកក្នុងប្រទេសកម្ពុជា | ២ |
| ៣-គោលការណ៍គ្រឹះជាមូលដ្ឋាន | ២ |
| ៤-គោលនយោបាយជាតិលើវិស័យធនធានទឹក | ៣ |
| ៤.១-ការភ្ជាប់នូវសន្តានុពលទឹកលើដី និងក្រោមដី | ៣ |
| ៤.១.១-ការវាយតំលៃធនធានទឹក | ៣ |
| ៤.១.២-ការគ្រប់គ្រង និងការអភិវឌ្ឍអាងទន្លេ | ៥ |
| ៤.២-ការចាត់ចែង ឬការធ្វើអាជីវកម្មសមស្រប | ៦ |
| ៤.២.១- ទឹកសំរាប់កសិកម្ម | ៧ |
| ៤.២.២- ទឹកសំរាប់ថាមពលអគ្គិសនី | ៧ |
| ៤.២.៣- ទឹកសំរាប់ឧស្សាហកម្ម-សិប្បកម្ម និងសេវាកម្មនានា | ៨ |
| ៤.២.៤- ទឹកសំរាប់ការប្រើប្រាស់ប្រចាំថ្ងៃ | ៩ |
| ៤.២.៥- ទឹកសំរាប់នាវាចរ និងទេសចរណ៍ | ១០ |
| ៤.២.៦- ប្រសិទ្ធភាពនៃការប្រើប្រាស់ទឹក និងភាពជាដៃគូ | ១១ |
| ៤.៣- ការបែងចែក និងការចែកចាយទឹកប្រកបដោយសមធម៌ | ១២ |
| ៤.៣.១- ការបែងចែក និងការចែកចាយទឹក | ១២ |
| ៤.៣.២- ព័ត៌មាន និងចំណេះដឹងជាសាធារណៈ | ១៤ |
| ៤.៤- ការកាត់បន្ថយនូវគ្រោះមហន្តរាយដែលកើតឡើងពីទឹក | ១៥ |
| ៤.៤.១- វិធានការនៃការកាត់បន្ថយគ្រោះមហន្តរាយ | ១៥ |
| ៤.៤.២- ការប្រមូលទិន្នន័យ ការព្យាករណ៍ និងការប្រកាសជូនដំណឹងជាមុន | ១៦ |
| ៤.៥- ការថែរក្សា ការការពារ និងនិរន្តរភាពនៃប្រព័ន្ធអេកូឡូស៊ី | ១៧ |
| ៤.៥.១- ក្របខ័ណ្ឌច្បាប់ | ១៨ |
| ៤.៥.២- ការពង្រឹងសមត្ថភាពស្ថាប័ន | ១៨ |
| ៤.៥.៣- ផ្នែកហិរញ្ញវត្ថុ | ១៩ |
| ៤.៦- និជ្ជភាពជាលក្ខណៈអន្តរជាតិនៃទឹក | ២០ |

៤.៧- ការគ្រប់គ្រងធនធានទឹកនៅតាមបណ្តោយព្រំដែនកម្ពុជា ជាមួយប្រទេសជិតខាង ២១

៤.៨- ការគ្រប់គ្រងទឹកតំបន់ឆ្នេរ និងទឹកសមុទ្រ ២២

៤.៨.១- ក្របខ័ណ្ឌស្ថាប័ន និងក្របខ័ណ្ឌបញ្ញត្តិ ២២

៤.៨.២- ចំណេះដឹងជាមូលដ្ឋាន ២៣

៤.៨.៣- សកម្មភាពរបស់មនុស្សនៅតំបន់ឆ្នេរ និងទឹកឆ្នេរ ២៤

៤.៨.៤- ទឹកសមុទ្រ ២៥

៥- ការអនុវត្តគោលនយោបាយ ២៦

៦-សេចក្តីសន្និដ្ឋាន ២៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី

លេខ: ៩២. សរណ

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៤

# សេចក្ដីជូនដំណឹង

## ស្ដីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៤

កាលពីថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០០៤ វេលាម៉ោង ៨.៣០ នាទី នៅទីស្ដីការគណៈរដ្ឋមន្ត្រីមានបើកសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្ដេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដើម្បីពិនិត្យពិភាក្សាលើ:

១-សេចក្ដីព្រាងគោលនយោបាយជាតិ លើវិស័យធនធានទឹក នៅក្នុងព្រះរាជាណាចក្រកម្ពុជា

២-សេចក្ដីព្រាងច្បាប់ស្ដីពីជលផល

៣-បញ្ហាផ្សេងៗ

**១. សេចក្ដីព្រាងគោលនយោបាយជាតិលើវិស័យធនធានទឹក នៅក្នុងព្រះរាជាណាចក្រកម្ពុជា**

គណៈរដ្ឋមន្ត្រីបានសំរេច:

១.១-នៅទំព័រទី ៥ :

-ចំណុច ទី ១ បន្ទាត់ទី ២ : បន្ថែមពាក្យ " ការផ្លាស់ប្ដូរចរន្តទឹក" បន្ទាប់ពីពាក្យ "ការប្រែប្រួលធារទឹកទន្លេ" ។

-ចំណុចទី ២ បន្ទាត់ទី ១ : បន្ថែមពាក្យ " ស្រះទឹក "បន្ទាប់ពីពាក្យ "អាងតំកល់ទឹក" ។

១.២-នៅទំព័រ ទី ៦ ចំណុចទី ៥ បន្ទាត់ទី ១: បន្ថែមពាក្យ "បឹងបួរ" នៅបន្ទាប់ពីពាក្យ " អាងទឹក" ។

នៅក្នុងអត្ថបទនៃសេចក្ដីព្រាងគោលនយោបាយជាតិលើវិស័យធនធានទឹក នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានពាក្យ "អាងទឹកធម្មជាតិ " ត្រូវកែសំរួលទៅជា : " អាងទឹក បឹងបួរធម្មជាតិ" ទាំងអស់ ។

១.៣-នៅទំព័រ ទី ៨ : កែសំរួលចំណងជើងចំណុច ៤.២.៣. " ទឹកសំរាប់ឧស្សាហកម្ម-សិប្បកម្ម " ទៅជា:" ទឹកសំរាប់ឧស្សាហកម្ម-សិប្បកម្ម និងសេវាកម្ម " ។

១.៤- នៅទំព័រទី ១៦ :

-ចំណុចទី ៤ បន្ទាត់ទី ២ : បន្ថែមពាក្យ "ការរៀបចំទីទួលសុវត្ថិភាព" បន្ទាប់ពីពាក្យ "មធ្យោបាយនានាដូចជា "។

-ចំណុច ៤.៤.២. លុបចោលឃ្លាចាប់ពី "សមត្ថភាពក្នុងការផ្តល់ទិន្នន័យចាំបាច់----------គណៈ-កម្មការទន្លេមេគង្គ (MRC) ក៏ដោយ ។"

១.៥-នៅទំព័រ ទី ២១ :

-ចំណុចទី ១ : កែសំរួលទៅជា : " ចាត់វិធានការចាំបាច់ និងប្រើប្រាស់នូវរាល់មធ្យោបាយនានា ដើម្បីសហការអោយបានជិតស្និទ្ធជាមួយបណ្តាប្រទេស ដែលប្រើប្រាស់ទឹកបណ្តាទន្លេ ព្រែក ស្ទឹង បឹងបួរ និងធានានូវការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព អោយមានការគោរពផលប្រយោជន៍គ្នាទៅវិញទៅមក ។"

-ចំណុចទី ២ បន្ទាត់ទី ២ និងទី ៣ លុបឃ្លា :" គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងគណៈកម្មការទន្លេមេគង្គ (MRC) " ហើយជំនួសដោយ : " ប្រទេសក្នុងតំបន់ "។

១.៦-ទំព័រ ទី ២២ ចំណុច ៤.៨ បន្ទាត់ចុងក្រោយ:" រួចហើយ-------និងទឹកសមុទ្រឡើយ ។" កែសំរួលទៅជា: " រួចហើយ ប៉ុន្តែឯកសារនៅពុំទាន់គ្រប់គ្រាន់នៅឡើយ រាជរដ្ឋាភិបាលនឹងបន្តខិតខំការកសាងលិខិតបទដ្ឋាន និងឯកសារនានា ថែមទៀតដើម្បីបញ្ជាក់អំពីការគ្រប់គ្រងទឹកឆ្នេរ និងទឹកសមុទ្រ ។"

ក្រៅពីការកែសំរួលខាងលើ គណៈរដ្ឋមន្ត្រីបានឯកភាពទាំងស្រុងតាមខ្លឹមសារនៃសេចក្តីព្រាងគោលនយោបាយជាតិលើវិស័យធនធានទឹក នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលក្រសួង ធនធានទឹក និងឧតុនិយម ក្រុមសង្កេតការណ៍ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងអង្គប្រជុំអន្តរក្រសួងបានស្នើឡើងមកនេះ។ ចន្លឹមនេះ គណៈរដ្ឋមន្ត្រីសំរេចប្រគល់ភារកិច្ចជូនក្រសួងធនធានទឹក និងឧតុនិយម សហការជាមួយទីស្តីការគណៈរដ្ឋមន្ត្រី រៀបចំកែសំរួលពាក្យពេចន៍ឡើងវិញ និងធ្វើការបកប្រែជាភាសាអង់គ្លេស អោយបានត្រឹមត្រូវតាមអត្ថបទភាសាខ្មែរ រួចបញ្ជូនឯកសារគោលនយោបាយជាតិនេះទៅធនាគារអភិវឌ្ឍន៍អាស៊ី (ADB) អោយបានទាន់ពេលវេលា។

## ២. សេចក្តីព្រាងច្បាប់ស្តីពីជលផល

គណៈរដ្ឋមន្ត្រីបានសំរេចលើកការពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីជលផលនេះ ទៅសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនៅសប្តាហ៍ក្រោយ ។

## ៣. បញ្ហាផ្សេងៗ

គណៈរដ្ឋមន្ត្រីបានសំរេច :

៣.១-ធ្វើការកោតសរសើរដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលកន្លងមកបានចាត់វិធានការទាន់ពេលវេលា ក្នុងការទប់ស្កាត់ការនាំចូលយកមកចិញ្ចឹម និងលក់ដូរលើទីផ្សារនៅកម្ពុជា ព្រមទាំងជួយបំផ្លាញ

ត្រីកាបទឹកសាប មានប្រភពមកពីទន្លេ **អាម៉ាហ្សូន (Amazon)** ។

ទន្ទឹមនេះ គណៈរដ្ឋមន្ត្រីបានសំរេចប្រគល់ភារកិច្ចជូនអាយកដ្ឋាន ជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើការអប់រំ ពន្យល់ និងណែនាំអំពីផលប៉ះពាល់បណ្តាលមកពីការនាំចូលពូជត្រីនេះមកកម្ពុជា ដល់មតិសាធារណជន តាមវិទ្យុ ទូរទស្សន៍ និងបណ្តាញពត៌មាននានា ។

៣.២-ប្រគល់ភារកិច្ចជូនក្រសួងសុខាភិបាលចាត់វិធានការទប់ទល់នឹងករណីជំងឺ **សារស៍ (SARS)** ដែលកន្លងមកថ្មីៗនេះ មានកើតឡើងមួយករណីជាថ្មីម្តងទៀតនៅតំបន់**ក្វាងតុង**ប្រទេសចិន ។

៣.៣-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គយ និងរដ្ឋាករ) ក្រសួងពាណិជ្ជកម្ម (កាំកុងត្រូល) ក្រសួងសុខាភិបាល ក្រសួងមហាផ្ទៃ និងក្រសួងពត៌មាន ព្រមទាំងអាជ្ញាធរខេត្តជាប់ព្រំដែន ដើម្បីរៀបចំកិច្ចប្រជុំពិភាក្សារកវិធានការទប់ស្កាត់ការរីករាលដាលនៃ **ជំងឺផ្តាសាយមាន់ (Bird Flu)** ដែលកំពុងកើតមានឡើងនៅប្រទេសជិតខាងនៃប្រទេសកម្ពុជា និងនៅប្រទេសមួយចំនួនក្នុងទ្វីបអាស៊ី សំដៅធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអោយបានយល់ជ្រួតជ្រាប និងចៀសវាងការប៉ះពាល់ដល់ចិត្តសាស្ត្រអ្នកទេសចរបរទេស ដែលនឹងមកធ្វើទស្សនកិច្ចនៅកម្ពុជា ។

៣.៤-ប្រគល់ភារកិច្ចជូនក្រសួងមហាផ្ទៃត្រៀមផ្តល់កិច្ចសហការជាមួយភាគីថៃ ដើម្បីទប់ស្កាត់ការនាំចូល និងចរាចរក្នុងទីផ្សារកម្ពុជា នូវប្រភេទថ្នាំញៀនថ្មី ដែលរាជរដ្ឋាភិបាលថៃនឹងប្រកាសនៅពេលខាងមុខនេះ ។

ទទួលបានសេចក្តីជូនដំណឹងនេះ គ្រប់ក្រសួង ស្ថាប័ន និងសាលាខេត្ត-ក្រុង ដែលមានការពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់អនុវត្តអោយទទួលបានលទ្ធផលជាវិជ្ជមាន ៕

**ទេសរដ្ឋមន្ត្រី**

**សុខ អាន**

**ចំលងជូន :**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធ

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី

-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

-សាលាខេត្ត-ក្រុង

-ឯកសារ-កាលប្បវត្តិ

## ១. សេចក្តីផ្តើម

តាមលក្ខណៈភូមិសាស្ត្រ ព្រះរាជាណាចក្រកម្ពុជាត្រូវបានចាត់ទុកថា ជាប្រទេសមួយសម្បូរទៅដោយធនធានទឹក។ ទន្លេ ស្ទឹង បឹងបួរ ល្អាងទឹកធម្មជាតិក្រោមដី និងសមុទ្រជាដើម គឺជាប្រភពធនធានទឹកដ៏សំខាន់សំរាប់បំរើឱ្យដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដូចជា កសិកម្ម ឧស្សាហកម្ម-សិប្បកម្ម ថាមពលអគ្គិសនី នាវាចរ វប្បធម៌ ទេសចរណ៍ ការទ្រទ្រង់ប្រព័ន្ធអេកូឡូស៊ី និងជីវភាពរស់នៅប្រចាំថ្ងៃ។

ប្រព័ន្ធទន្លេមេគង្គកម្ពុជា ដោយរួមបញ្ចូលទាំងប្រព័ន្ធបឹងទន្លេសាបផង មានតួនាទីយ៉ាងសំខាន់ក្នុងការថែរក្សា និងទ្រទ្រង់ប្រព័ន្ធអេកូឡូស៊ី ហើយផ្តល់នូវធនធានជាមូលដ្ឋានសំរាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

ប្រជាជនកម្ពុជាភាគច្រើនដែលរស់នៅតាមជនបទ បានប្រឈមមុខទៅនឹងកង្វះទឹកយ៉ាងខ្លាំងនារដូវប្រាំង ហើយនិងកួនរដូវប្រាំងនៅក្នុងរដូវវស្សាផងដែរ។ ផ្ទុយទៅវិញ នៅរដូវវស្សាមានទឹកសម្បូរហូរហៀរ ។ ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពពុំមានគ្រប់គ្រាន់ និងមានលក្ខណៈចាស់ទ្រុឌទ្រោមដែលនាំឱ្យមានផលលំបាកចំពោះការស្តុកទឹក ការផ្គត់ផ្គង់ទឹក ការបែងចែកទឹក និងការផលិតស្បៀង។

ការកើនឡើងនូវសារធាតុបំពុល និងការរងកករ ដោយសារការកកដី និងសំណល់ ដែលបង្កឡើងដោយសារទីក្រុង តំបន់ឧស្សាហកម្ម តំបន់កសិកម្ម និងការកាប់ព្រៃឈើ នៅតាមតំបន់ឆ្នេរអាចបណ្តាលឱ្យមានការបំពុលទឹកសមុទ្រ។ បន្ថែមលើនេះទៀត ការធ្វើនាវាចរ និងការធ្វើអាជីវកម្មប្រេង និងឧស្ម័នក៏អាចប៉ះពាល់ដល់ធនធានទឹកផងដែរ។

ទឹកសមុទ្រនៃព្រះរាជាណាចក្រកម្ពុជាទាមទារឱ្យមានការគ្រប់គ្រងដោយប្រុងប្រយ័ត្នជាពិសេសនៅតាមបណ្តោយឆ្នេរ និងតំបន់មាត់ពាម ដើម្បីធានាដល់ការទ្រទ្រង់ប្រព័ន្ធអេកូឡូស៊ី ជលផល ព្រមទាំងផ្តល់ជាមូលដ្ឋានដល់សកម្មភាពសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ដែលពាក់ព័ន្ធដល់ការងារជលផល និងទេសចរណ៍។

នៅក្នុងពេលប៉ុន្មានឆ្នាំខាងមុខនេះ ចំនួនប្រជាជននឹងមានសន្ទុះកើនឡើង ហើយការអភិវឌ្ឍសេដ្ឋកិច្ចនឹងមានការរីកចំរើន ដែលធ្វើឱ្យតំរូវការទឹកមានកំរិតខ្ពស់ និងជាសំពាធមួយដ៏ធ្ងន់ធ្ងរប៉ះពាល់មកលើធនធានទឹក និងបរិស្ថានជាតិ ។ ដូច្នេះរាជរដ្ឋាភិបាលកម្ពុជា ចាំបាច់ត្រូវកំណត់ឱ្យបានច្បាស់លាស់នូវចក្ខុវិស័យទឹកនៅក្នុងសង្គម ដើម្បីធានាឱ្យមានការប្រើប្រាស់ទឹកប្រកបដោយគតិបណ្ឌិត និងយុត្តិធម៌ ។

គោលនយោបាយជាតិលើវិស័យធនធានទឹកសំរាប់ ÷

- ការពារ គ្រប់គ្រង និងប្រើប្រាស់ធនធានទឹកប្រកបដោយប្រសិទ្ធភាព សមធម៌ និងនិរន្តរភាព
- ប្រមើលមើលទុកជាមុន និងមានវិធានការជួយដល់ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយលើបញ្ហាប្រឈមមុខនានា ដែលអាចកើតមានឡើងក្នុងវិស័យទឹក

- រៀបចំ និងអនុវត្តយុទ្ធសាស្ត្រជាតិ និងការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រតាមផ្នែកនានាស្តីពីការគ្រប់គ្រងធនធានទឹក
- តំរង់ទិស នូវរាល់សកម្មភាពរបស់ស្ថាប័នគ្រប់លំដាប់ថ្នាក់ ផ្នែកឯកជន និងសាធារណៈ ក្នុងការអភិវឌ្ឍ ការប្រើប្រាស់ និងការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- កែលំអ ព្រមទាំងលើកកំពស់ជីវភាពប្រជាពលរដ្ឋឱ្យបានល្អប្រសើរ ដើម្បីឈានទៅសំរេចបាននូវគោលនយោបាយជាតិស្តីពីការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយនិរន្តរភាព ។

## ២. ចក្ខុវិស័យទឹកក្នុងប្រទេសកម្ពុជា

ដើម្បីធានាឱ្យបាននូវការប្រើប្រាស់ធនធានទឹកប្រកបដោយប្រសិទ្ធភាព និរន្តរភាព គតិបណ្ឌិត និងយុត្តិធម៌ រាជរដ្ឋាភិបាលកម្ពុជាមានចក្ខុវិស័យទឹកដូចខាងក្រោម ÷

- ផ្តល់លទ្ធភាពឱ្យដល់ជនគ្រប់រូប ក្នុងការប្រើប្រាស់ទឹកសំរាប់បរិភោគគ្រប់គ្រាន់ ប្រកបដោយអនាម័យល្អ មានសុវត្ថិភាព និងតំលៃសមស្រប
- ផ្គត់ផ្គង់ទឹកគ្រប់គ្រាន់ដល់វិស័យកសិកម្ម ឧស្សាហកម្ម និងសកម្មភាពសេដ្ឋកិច្ចផ្សេងៗទៀត
- ដោះស្រាយ និងកាត់បន្ថយឱ្យបានជាអតិបរិមា នូវគ្រោះគំរាមកំហែងដល់អាយុជីវិត និងការរស់នៅប្រចាំថ្ងៃ ពីមហន្តរាយដែលបង្កឡើងដោយទឹក
- គ្រប់គ្រងបរិស្ថានធនធានទឹកដែលគ្មានសារធាតុបំពុល ។

## ៣. គោលការណ៍គ្រឹះជាមូលដ្ឋាន

បច្ចុប្បន្នប្រទេសជាច្រើននៅលើពិភពលោកបានកំណត់យកគោលការណ៍គ្រឹះជាមូលដ្ឋានជាច្រើនពាក់ព័ន្ធនឹងវិស័យទឹកដែលក្នុងនោះមានគោលការណ៍មួយបានចែងថាទឹកគឺជាទ្រព្យសម្បត្តិរបស់រដ្ឋហើយមិនមែនជាកម្មសិទ្ធិរបស់បុគ្គលណាមួយឡើយ ។

ដើម្បីធានាឱ្យមានប្រសិទ្ធភាព និងនិរន្តរភាពនៃការគ្រប់គ្រងធនធានទឹកនៅក្នុងប្រទេសកម្ពុជា រាជរដ្ឋាភិបាលកំណត់យកគោលការណ៍គ្រឹះជាមូលដ្ឋានសំខាន់ៗដូចជា ÷

- ការគ្រប់គ្រងទឹក និងធនធានទឹកជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល
- រាល់គំរោងការងារទឹក ត្រូវរៀបចំឡើងផ្អែកលើទិន្នន័យ និងពត៌មានស្តីពីទឹក ស្របតាមផែនការអភិវឌ្ឍន៍ធនធានទឹកជាតិ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ផែនការបរិស្ថានជាតិ និងគោលការណ៍អភិវឌ្ឍតំបន់ដោយធានាបាននូវតុល្យភាពនៃការប្រើប្រាស់ទឹកនាពេលបច្ចុប្បន្ន និងពេលអនាគត

- បុគ្គលគ្រប់រូប មានសិទ្ធិប្រើប្រាស់ធនធានទឹកក្នុងបរិមាណមួយមិនលើសពីសេចក្តីត្រូវការចាំបាច់នៅក្នុងគ្រួសារនីមួយៗដូចជា: សំរាប់ការហូបចុក បោកគក់ ងូត តំរូវការជាមូលដ្ឋានប្រចាំថ្ងៃ និងសំរាប់បំពេញដល់ការចិញ្ចឹមសត្វ ត្រី ការស្រោចស្រពសួនច្បារ ដំណាំ
- ការប្រើប្រាស់ និងការអភិវឌ្ឍលើវិស័យធនធានទឹក ត្រូវធានាឱ្យបាននូវប្រសិទ្ធភាព និរន្តរភាព និងមិនបង្កឱ្យប៉ះពាល់ដល់បរិស្ថាន។

# ៤. គោលនយោបាយជាតិលើវិស័យធនធានទឹក

## ៤.១. ការគ្រប់គ្រងសក្តានុពលទឹកលើដី និងក្រោមដី

### ៤.១.១. ការវាយតំលៃធនធានទឹក

ប្រទេសកម្ពុជា ជាប្រទេសមួយសម្បូរទៅដោយប្រភពធនធានទឹក ក្នុងនោះទឹកលើដីមានចំនួនប្រមាណ ៧៥.០០០ លានម៣ ដោយមិនគិតពីបរិមាណទឹកដែលស្ថិតក្នុងតំបន់ផ្ទៃរងទឹកភ្លៀងនៅតំបន់មាត់សមុទ្រ និងទឹកក្រោមដីដែលមានចំនួនប្រមាណ ១៧.៦០០ លានម៣។ បរិមាណទឹកនេះ មានច្រើនជាងមួយរយដងនៃបរិមាណទឹកដែលបានប្រើប្រាស់នាពេលបច្ចុប្បន្ន ។ ក្នុងមួយឆ្នាំជាមធ្យមប្រទេសកម្ពុជា បានទទួលអំណោយផលទឹកភ្លៀងប្រមាណពី ១.៤០០ មម ទៅ ៣.៥០០ មម។

ក្នុងមួយឆ្នាំៗបរិមាណទឹកទន្លេមេគង្គប្រមាណ ៤៧៥.០០០ លានម៣ បានហូរកាត់ប្រទេសកម្ពុជាធ្លាក់ចុះទៅក្នុងសមុទ្រចិនភាគខាងត្បូង ។

បច្ចុប្បន្ននេះទឹកត្រូវបានប្រើប្រាស់ក្នុងវិស័យផ្សេងៗ ដូចជា ការប្រើប្រាស់ក្នុងគ្រួសារ កសិកម្មឧស្សាហកម្ម-សិប្បកម្ម ការផលិតថាមពលអគ្គិសនី នាវាចរ និងទេសចរណ៍។ ល។ តាមការប៉ាន់ស្មានបរិមាណសរុបនៃការប្រើប្រាស់ទឹកនាពេលបច្ចុប្បន្នក្នុងមួយឆ្នាំមានចំនួនប្រមាណ ៧៥០ លានម៣ ក្នុងនោះចំនួនប្រមាណ ៩៥% សំរាប់វិស័យកសិកម្ម។ នាពេលបច្ចុប្បន្ននេះ ការក្តាប់ទិន្នន័យ និងពត៌មានស្តីពីបរិមាណនៃការប្រើប្រាស់ទឹកលើវិស័យផ្សេងៗនៅមានកំរិត។

ប្រភពទឹកក្រោមដីក៏មានសារៈសំខាន់ផងដែរនៅក្នុងការផ្គត់ផ្គង់ទឹក ការថែរក្សានូវគុណភាពទឹកនិងជាប្រភពទឹកសាបដ៏សំខាន់ សំរាប់ការបរិភោគប្រចាំថ្ងៃរបស់ប្រជាជន ការស្រោចស្រពដំណាំកសិកម្មឧស្សាហកម្ម ហើយដែលអាចមានលទ្ធភាពផ្តល់ទឹកបានស្ទើរពេញមួយឆ្នាំ។ នាពេលបច្ចុប្បន្ននេះ ការបែងចែក និងការកំណត់បរិមាណទឹកក្រោមដី ពុំទាន់មានទិន្នន័យ និងពត៌មានច្បាស់លាស់នៅឡើយទេ ។

នៅរដូវវស្សាកំរិតកំពស់ទឹក និងធារទឹកនៅតាមទន្លេ ស្ទឹង បឹងបួរនានាបានកើនឡើងយ៉ាងខ្ពស់ គឺដោយសារឥទ្ធិពលនៃបរិមាណលំហូរទឹកភ្លៀងយ៉ាងខ្លាំង ។ ទន្ទឹមនឹងនេះដែរ ក៏បានធ្វើឱ្យគុណភាពទឹកមានការប្រែប្រួលទាំងលក្ខណៈគីមី និងលក្ខណៈរូប ព្រមទាំងមានការហូរច្រោះដាច់ដី ដែលជាហេតុធ្វើឱ្យទន្លេ ស្ទឹង បឹងបួរទាំងនោះទទួលនូវការរងកករដីយ៉ាងខ្លាំង ។ ផ្ទុយទៅវិញ នៅរដូវប្រាំង-ការស្ទើរ

ខូចនូវគុណភាពទឹក ក៏មានការថយចុះគួរអោយកត់សំគាល់ផងដែរ ដោយសារភាពកខ្វក់មានភាពរលាយតិចតួចបំផុត ។ ម្យ៉ាងទៀតការកើនឡើងនៃចំនួនប្រជាជន និងកំណើននៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ក៏នឹងឈានទៅគំរាមកំហែងដល់គុណភាពទឹកផងដែរ ។

រាល់បញ្ហាទាំងអស់ខាងលើដែលពាក់ព័ន្ធទៅនឹងបរិមាណ និងគុណភាពនៃធនធានទឹក ទាមទារឱ្យមានការវាយតំលៃត្រឹមត្រូវ និងច្បាស់លាស់ដែលជាមូលដ្ឋានគ្រឹះសំរាប់កំណត់នូវគោលនយោបាយក្នុងការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាព ។

ដើម្បីជំនះបាននូវរាល់បញ្ហាខាងលើ រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយក្នុងការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាពដូចតទៅ ៖

១- ជំរុញការសិក្សា និងការស្រាវជ្រាវបន្ថែមលើវិស័យទឹក ដើម្បីជាមូលដ្ឋានក្នុងការវាយតំលៃលើការងារគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹកឱ្យមាននិរន្តរភាព ដោយមានការចូលរួមសហការពីស្ថាប័នពាក់ព័ន្ធ គ្រឹះស្ថានឧត្តមសិក្សា អង្គការជាតិ និងអន្តរជាតិនានា ។

២- ត្រួតពិនិត្យជាប់ជាប្រចាំនូវស្ថានភាពធនធានទឹកលើដី និងក្រោមដី ដើម្បីជាមូលដ្ឋានក្នុងការគ្រប់គ្រង និងឆ្លើយតបទៅនឹងការផ្លាស់ប្តូរ និងនិន្នាការមិនល្អ ដោយជូនពត៌មានជាសាធារណៈស្តីអំពីស្ថានភាពធនធានទឹកជាតិ និងការរៀបចំផែនការសំរាប់អនាគត ។

៣-ជំរុញដល់ស្ថាប័នរដ្ឋ ឯកជន អង្គការជាតិ និងអន្តរជាតិដទៃទៀត ដែលកំពុងដំណើរការអនុវត្តគំរោងដែលពាក់ព័ន្ធនឹងទឹក ឱ្យផ្ញើទិន្នន័យ និងពត៌មានព្រមទាំងរបាយការណ៍ ដែលជាលទ្ធផលនៃការអនុវត្តគំរោងមកឱ្យក្រសួងធនធានទឹក និងឧតុនិយម ដើម្បីចងក្រងបង្កើតជាទិន្នន័យរួមរបស់ជាតិ ។ ទិន្នន័យ និងពត៌មានទាំងនេះ នឹងត្រូវផ្ទេរ ព្រមទាំងផ្តល់ជូនដល់ស្ថាប័ននានានៃរាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវការចាំបាច់សំរាប់បំរើដល់កិច្ចអភិវឌ្ឍតាមវិស័យរបស់ខ្លួន ។

ក្រសួងធនធានទឹក និងឧតុនិយម ត្រូវរៀបចំនីតិវិធីក្នុងការគ្រប់គ្រងលើការផ្ទេរទិន្នន័យ និងពត៌មាន ដល់ស្ថាប័ននានានៃរាជរដ្ឋាភិបាលកម្ពុជា ។

៤-ត្រូវកំណត់ដាក់ឱ្យប្រើប្រាស់ជាសាធារណៈនូវរាល់ទិន្នន័យ និងពត៌មានពាក់ព័ន្ធនឹងទឹក ដែលជាកម្មសិទ្ធរបស់រដ្ឋ លើកលែងតែពត៌មានសំងាត់ និងមានសារៈសំខាន់ដល់ផ្នែកសន្តិសុខជាតិ ។

## ៤.១.២. ការគ្រប់គ្រង និងការអភិវឌ្ឍអាងទន្លេ

អាងទន្លេ និងល្អាងទឹកធម្មជាតិក្រោមដីគឺជាមូលដ្ឋានគ្រឹះសំរាប់ការរៀបចំផែនការ ការអភិវឌ្ឍ ការគ្រប់គ្រង និងការបែងចែកធនធានទឹកប្រកបដោយសមធម៌ និងនិរន្តរភាព ព្រមទាំងមូលដ្ឋានជីវៈរូបនៃវដ្តទឹក ។ នៅក្នុងប្រទេសកម្ពុជា បឹងបួរ និងតំបន់ដីសើម ក៏មានតួនាទីយ៉ាងសំខាន់នៅក្នុងវដ្តទឹកផងដែរ ព្រមទាំងធនធានដែលមាននៅក្នុងទឹក និងផលផលដែលប្រជាជនកម្ពុជាបានពឹងផ្អែកទាំងស្រុងសំរាប់ការផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃ ។

កន្លងមកការគ្រប់គ្រង និងការអភិវឌ្ឍលើអាងទន្លេនៅមានកំរិតនៅឡើយ ដោយខ្វះខាតនូវប្រភពធនធានមនុស្ស ថវិកា ច្បាប់ បច្ចេកវិទ្យា ។ ល ។ ដែលជាហេតុធ្វើអោយមានការចាប់យកដីធ្លី ការសាងសង់ ការកាប់ព្រៃឈើ និងការធ្វើអាជីវកម្មខុសច្បាប់ ។ បញ្ហាទាំងអស់ខាងលើនេះបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើអាងទន្លេដូចជា ការហូរច្រោះដី ការរងកករដីនៅបាតទន្លេ-ស្ទឹង ការប្រែប្រួលគុណភាពទឹក ការប្រែប្រួលទ្រង់ទ្រាយ ការផ្លាស់ប្តូររបបជលសាស្ត្រ ទឹកជំនន់ និងភាពរាំងស្ងួត ព្រមទាំងប៉ះពាល់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិផងដែរ ។

នៅរដូវប្រាំង អាងទន្លេមួយចំនួនពុំមានទឹកគ្រប់គ្រាន់សំរាប់បំពេញនូវតំរូវការរបស់មនុស្ស និងសំរាប់ទ្រទ្រង់ប្រព័ន្ធអេកូឡូស៊ី ។ ចំណែកឯនៅក្នុងរដូវវស្សាវិញ ទឹកមានបរិមាណលើសពីសេចក្តីត្រូវការនៃការប្រើប្រាស់ ។ តាមការពិត ការសាងសង់អាងត្រកល់ទឹក ប្រព័ន្ធដោះទឹក និងប្រឡាយនាំទឹក ដើម្បីកែប្រែ និងធានាអោយបាននូវតុល្យភាពទឹក ដែលមានពីធម្មជាតិនៃអាងទន្លេ អាចជួយដោះស្រាយនូវអតុល្យភាពរវាងការផ្គត់ផ្គង់ និងតំរូវការទឹកបាន ។ ប៉ុន្តែការងារនេះ ទាមទារនូវថវិកា បច្ចេកទេស និងកំលាំងពលកម្មយ៉ាងច្រើន រីឯការជះឥទ្ធិពលទៅលើបរិស្ថានធម្មជាតិ និងសង្គមពីការងារខាងលើនេះតំរូវឱ្យមានការវិភាគដោយប្រុងប្រយ័ត្នមុននឹងអនុវត្ត ។

ដើម្បីដោះស្រាយបាននូវរាល់បញ្ហាខាងលើនេះឱ្យបានជោគជ័យ រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយដូចតទៅ ៖

១- ជំរុញការសិក្សា និងរៀបចំផែនការអភិវឌ្ឍអាងទន្លេសំរាប់រយៈពេលខ្លី មធ្យម និងវែង ព្រមទាំងគិតគូរដល់ការប្រែប្រួលធារទឹកទន្លេ ការផ្លាស់ប្តូរចរន្តទឹក និងល្អាងទឹកធម្មជាតិក្រោមដី ដើម្បីធានាដល់ការប្រើប្រាស់ធនធានទឹកនាបច្ចុប្បន្ន និងពេលអនាគត ។

២- ជំរុញឱ្យមានការពង្រឹង និងពង្រីកបន្ថែមនូវអាងត្រកល់ទឹក ស្រះទឹក ប្រឡាយបញ្ជូនទឹក និងប្រព័ន្ធដោះទឹក ដើម្បីធានាដល់ការផ្គត់ផ្គង់ទឹក និងនិរន្តរភាព ។

៣- អនុវត្តនូវវិធីសាស្ត្រចំរុះចំពោះការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹក ដោយគិតគូរឱ្យបានច្បាស់លាស់ពីប្រភពទឹក ការផ្សារភ្ជាប់គ្នារវាងធនធានទឹកជាមួយនឹងផ្នែកផ្សេងទៀតនៃបរិស្ថាន ការប្រែប្រួលនូវតំរូវការរបស់មនុស្ស និងបរិស្ថានមកលើធនធានទឹក ព្រមទាំងតំរូវការនូវវិធីសាស្ត្រផ្សេងនានា ក្នុងការអនុវត្តការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ។

៤- ផ្តោតការយកចិត្តទុកដាក់ជាអាទិភាពទៅលើទីជំរាល និងស្រទាប់ទឹកធម្មជាតិក្រោមដី ដែលកំពុងត្រូវបានគំរាមកំហែងយ៉ាងធ្ងន់ធ្ងរពីសកម្មភាពរបស់មនុស្ស ព្រមទាំងទៅលើការប្រជែងគ្នាក្នុងការប្រើប្រាស់ទឹក ដែលនឹងក្លាយទៅជាបញ្ហាមួយចំពោះមុខ ដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងនិរន្តរភាព ។

៥- ពង្រឹងលើកិច្ចអភិរក្សអាងទឹក បឹងបួរធម្មជាតិដែលមានលទ្ធភាពស្តុកទឹក ដើម្បីជួយសំរួលដល់ការកាត់បន្ថយនូវទឹកជំនន់ ព្រមទាំងរក្សាបាននូវប្រព័ន្ធអេកូឡូស៊ី ។

៦- អភិរក្សនូវលទ្ធភាពនៃស្រទាប់ទឹកធម្មជាតិក្រោមដី ជាពិសេសចំពោះស្រទាប់ទឹកធម្មជាតិក្រោមដីដែលទទួលរងការបំពុលបំផ្លាញយ៉ាងខ្លាំង ដើម្បីផ្តល់នូវប្រភពទឹកប្រកបដោយគុណភាពខ្ពស់ និងនិរន្តរភាព ព្រមទាំងធានាបាននូវតុល្យភាពរវាងការប្រើប្រាស់ និងការបំពេញមកវិញនូវធារទឹកទៅក្នុងស្រទាប់ទឹកធម្មជាតិក្រោមដី ។

៧- បង្កើនការយល់ដឹង និងជំរុញការរៀបចំ ការអនុវត្តនូវផែនការគ្រប់គ្រង និងផែនការអភិវឌ្ឍអាងទន្លេ ដោយមានការចូលរួមសហការពីស្ថាប័នពាក់ព័ន្ធ អ្នកពាក់ព័ន្ធ និងអ្នកទទួលផល ។

## ៤.២. ការចាត់ចែង ឬការធ្វើអាជីវកម្មសមស្រប

ទឹក ដើរតួនាទីយ៉ាងសំខាន់ ក្នុងការសំរេចឱ្យបាននូវគោលដៅចំបងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍសេដ្ឋកិច្ច សន្តិសុខស្បៀង និងការអភិរក្សបរិស្ថាន។ ទឹកគឺជាធនធានមូលដ្ឋានទ្រទ្រង់ដល់វិស័យនានាដូចជា កសិកម្ម ឧស្សាហកម្ម ថាមពល ការប្រើប្រាស់ក្នុងគ្រួសារ នាវាចរ ទេសចរណ៍ ជលផល និងការថែរក្សាប្រព័ន្ធអេកូឡូស៊ី ។ ម្ល៉ោះហើយការបែងចែងទឹកត្រូវតែធ្វើឱ្យមានតុល្យភាពចំពោះតំរូវការក្នុងវិស័យខាងលើនេះ ដើម្បីប្រើប្រាស់ទឹកអស់ពីលទ្ធភាព សំរាប់ផលប្រយោជន៍ជាតិ ។

ដើម្បីដោះស្រាយនូវបញ្ហាខាងលើ រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយអភិវឌ្ឍ និងគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាព ដើម្បីទ្រទ្រង់ដល់ការធ្វើឱ្យសំរេចបាននូវគោលដៅទាំងពីរ គឺការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយនិរន្តរភាពដោយធ្វើឱ្យមានតុល្យភាពតំរូវការទឹកនៃវិស័យសេដ្ឋកិច្ចនានា ។

### ៤.២.១. ទឹកសំរាប់កសិកម្ម

ប្រជាជនកម្ពុជាភាគច្រើនរស់នៅតាមជនបទ និងប្រកបរបរកសិកម្ម ហើយបានពឹងផ្អែកភាគច្រើនទៅលើទឹកភ្លៀង ។ ជារៀងរាល់ឆ្នាំ ប្រជាជនបានជួបប្រទះនូវកង្វះខាតទឹក គ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់ គឺជាបញ្ហាដែលធ្វើឱ្យប៉ះពាល់ដល់ការងារបង្កបង្កើនផលកសិកម្ម ។

បច្ចុប្បន្ននេះហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រដែលមានស្រាប់ច្រើនមានលក្ខណៈចាស់ទ្រុឌទ្រោមនិងពុំទាន់មានលទ្ធភាពគ្រប់គ្រាន់ដើម្បីធានាដល់ការងារបង្កបង្កើនផលនៅឡើយ ។ម្យ៉ាងទៀត ការចូលរួមពីអ្នកទទួលផលលើការរៀបចំផែនការ ការសាងសង់ ការគ្រប់គ្រង និងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធដោះទឹក ទំនប់ការពារទឹកជំនន់នៅមានកំរិតនៅឡើយ ។

ដើម្បីដោះស្រាយបាននូវរាល់បញ្ហាខាងលើនេះ ព្រមទាំងធានាបាននូវការផ្គត់ផ្គង់ទឹកគ្រប់គ្រាន់ដល់ការងារបង្កបង្កើនផល រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយដូចតទៅ ÷

១- ផ្តល់នូវបរិមាណទឹកទៅតាមពេលវេលា និងទីកន្លែងដែលកសិករត្រូវការទៅតាមលទ្ធភាពធនធានទឹកដែលមាន និងបច្ចេកទេសជាក់ស្តែង ។

២- បន្តជំរុញការស្តារ និងអភិវឌ្ឍនូវប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធដោះទឹក និងទំនប់ការពារជំនន់នៅទីកន្លែងដែលមានសក្តានុពលសេដ្ឋកិច្ច និងសង្គមដែលត្រូវផ្តល់ទឹកដល់ផលិតកម្មកសិកម្ម និងកាត់បន្ថយនូវផលវិបាកជាអវិជ្ជមាន ដែលបណ្តាលមកពីទឹកច្រើនលើសលប់ ។

៣- ជំរុញការផ្សព្វផ្សាយបច្ចេកវិទ្យាគ្រប់គ្រងទឹកសមស្របមួយក្នុងតំបន់កសិកម្ម ដែលពឹងផ្អែកលើទឹកភ្លៀង ឱ្យចេះរក្សាទឹកទុក រក្សាសំណើមក្នុងដី និងប្រើប្រាស់ស្រះកសិដ្ឋាន ។

៤-បន្តពង្រឹង និងពង្រីកបន្ថែមនូវសហគមន៍កសិករប្រើប្រាស់ទឹក ដើម្បីចូលរួមក្នុងការគ្រប់គ្រងទឹក បែងចែកទឹក និងថែរក្សានូវប្រព័ន្ធធារាសាស្ត្រប្រកបដោយប្រសិទ្ធភាពខ្ពស់ និងរក្សាបាននូវនិរន្តរភាព ។

៥-កាត់បន្ថយឱ្យបានជាអតិបរិមានូវផលប៉ះពាល់ទៅលើធនធានទឹក ដែលបណ្តាលមកពីការប្រើប្រាស់សារធាតុគីមីគ្រប់យ៉ាងក្នុងផលិតកម្មកសិកម្ម ដោយលើកទឹកចិត្តឱ្យធ្វើកសិកម្មចំរុះជាដើម ។

### ៤.២.២. ទឹកសំរាប់ថាមពលអគ្គិសនី

នៅក្នុងប្រទេសកម្ពុជាសក្តានុពលធនធានទឹកសំរាប់បំរើឱ្យវិស័យថាមពលអគ្គិសនីមានចំនួនប្រមាណ១០.០០០ MW ក្នុងនោះ៥០ភាគរយនៅលើទន្លេមេ ៤០ភាគរយនៅលើដៃរបស់វា និង១០ភាគរយទៀតនៅតាមតំបន់ឆ្នេរ ប៉ុន្តែការទាញយកផលប្រយោជន៍ពីសក្តានុពលធនធានទឹកខាងលើនេះមាន

តែ ១៣ MW ប៉ុណ្ណោះ ក្នុងនោះស្ថានីយ៍វារីអគ្គិសនីអូរជុំទិ II មាន ១ MW និងស្ថានីយ៍វារីអគ្គិសនីគីរីរម្យទី I មាន ១២ MW ហើយស្ថានីយ៍វារីអគ្គិសនីកំចាយក៏ជិតនឹងដំណើរការសាងសង់ផងដែរ ។ ការអភិវឌ្ឍវិស័យថាមពលខាងលើនេះ គឺមានសារៈប្រយោជន៍សំខាន់ណាស់ ព្រោះអាចជំរុញសេដ្ឋកិច្ចកម្ពុជាឱ្យចេញផុតពីភាពក្រីក្រ ហើយការកសាងនេះមិនគ្រាន់តែផ្តល់ថាមពលដល់ទីក្រុង និងជនបទប៉ុណ្ណោះទេ គឺថែមទាំងផ្តល់ទឹកសំរាប់កសិកម្មពេញលេញ ការការពារទឹកជំនន់ និងការរីកចំរើនកសិ-ឧស្សាហកម្មនៅតាមជនបទ ដែលជាទីផ្សារសំខាន់របស់កសិករទៀត។ សព្វថ្ងៃប្រជាជនកម្ពុជា ប្រមាណ ១៥% បានប្រើប្រាស់ថាមពលអគ្គិសនីដែលដើរដោយប្រេងឥន្ធនៈ ។

ដើម្បីដោះស្រាយបាននូវរាល់បញ្ហាខាងលើ និងជំរុញដល់ការទាញយកផល និងការអភិវឌ្ឍថាមពលវារីអគ្គិសនីឱ្យអស់លទ្ធភាព រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយដូចតទៅ ÷

១-ជំរុញ និងលើកទឹកចិត្តដល់ការសិក្សាស្រាវជ្រាវចំពោះការអភិវឌ្ឍវិស័យថាមពលវារីអគ្គិសនីខ្នាតតូច មធ្យម និងធំ ទៅលើសក្តានុពលភាពនៃការប្រើប្រាស់ទឹក សំរាប់បំរើឱ្យវិស័យថាមពលអគ្គិសនី ដោយរួមបញ្ចូលទាំងផលប្រយោជន៍ និងតំលៃផងដែរ។

២-ជំរុញ និងលើកទឹកចិត្តដល់ការធ្វើវិនិយោគ និងការធ្វើអាជីវកម្មលើវិស័យថាមពលវារីអគ្គិសនី ខ្នាតតូច មធ្យម និងធំ រាប់បញ្ចូលទាំងវារីអគ្គិសនី ដែលអាចបំពេញដល់តំរូវការរបស់ប្រជាពលរដ្ឋក្រីក្រ ឬនៅតំបន់ដាច់ស្រយាល ដើម្បីទទួលបាននូវថាមពលអគ្គិសនីគ្រប់គ្រាន់ក្នុងការប្រើប្រាស់ប្រចាំថ្ងៃ ។

### ៤.២.៣. ទឹកសំរាប់ឧស្សាហកម្ម សិប្បកម្ម និងសេវាកម្ម

វិស័យឧស្សាហកម្ម-សិប្បកម្ម និងសេវាកម្ម ទូទៅជាវិស័យប្រើប្រាស់ទឹកដែលមានគុណភាពខ្ពស់ក្នុងបរិមាណតិចតួចប៉ុណ្ណោះ ។ ទឹកជាកត្តាដ៏សំខាន់មួយនៃផលិតកម្ម ប៉ុន្តែការចំណាយទៅលើថ្លៃប្រើប្រាស់ទឹកមិនមែនជាថ្នែកដ៏ធំមួយក្នុងតំលៃផលិតកម្មសរុបទេ ។ បច្ចុប្បន្ននេះ គ្រឹះស្ថានឧស្សាហកម្ម-សិប្បកម្ម និងសេវាកម្មមួយចំនួនអាចទិញទឹកទៅតាមតំរូវការ ប៉ុន្តែគ្រឹះស្ថានមួយចំនួនធំទៀតកំពុងប្រើប្រាស់នូវឧបករណ៍ប្រព្រឹត្តិកម្មសំអាតទឹកផ្ទាល់ខ្លួនដោយការត្រួតពិនិត្យពីស្ថាប័នជំនាញនៅមានកំរិត ។ ម្យ៉ាងទៀតគ្រឹះស្ថានឧស្សាហកម្ម - សិប្បកម្ម និងសេវាកម្ម អាចទំលាក់បន្ទុកបំពុលដ៏ធ្ងន់ធ្ងរមកលើប្រភពធនធានទឹកទាំងមូល នៅពេលដែលគ្រឹះស្ថានទាំងនោះបញ្ចេញសំណល់ចូលទៅក្នុងបរិស្ថានដែលនឹងអាចគំរាមកំហែងយ៉ាងខ្លាំងដល់គុណភាពទឹក ទាំងនៅលើដី ទាំងនៅក្រោមដី ។ ជាគោលការណ៍ ... បញ្ចេញចោលឮ្យស់លាស់ គឺងាយស្រួលក្នុងការគ្រប់គ្រង ដោយរាជរដ្ឋាភិបាលមាន ... លើការងារនេះ ។ បច្ចេកវិទ្យាសំរាប់ការគ្រប់គ្រងទឹកសំណល់រាវរួមមាន វិធីសាស្ត្រ ...

ឡើងវិញ វិធីសាស្ត្រក្នុងការកែច្នៃ និងការធ្វើប្រព្រឹត្តិកម្មសំអាតទឹកសំណល់រាវក្នុងរោងចក្រ គឺកំពុងតែអភិវឌ្ឍយ៉ាងសកម្ម ។ ប៉ុន្តែជាក់ស្តែង ការអនុវត្តមានការលំបាកដោយសារសមត្ថភាពស្ថាប័នក្នុងការអនុវត្តនៅមានកំរិត ដែលទាមទារនូវការពង្រឹងបន្ថែម ។

ទន្ទឹមនឹងនេះ គ្រឹះស្ថានជាច្រើនក្នុងការគ្រប់គ្រងប្រព័ន្ធទឹកសំណល់នៅមានកំរិតទាប ឬមិនទាន់មានបណ្តាញតភ្ជាប់ទៅនឹងបណ្តាញដោះទឹកសំណល់ក្នុងក្រុងនៅឡើយ ។

ដើម្បីជំនះបាននូវរាល់បញ្ហាទាំងនេះ និងឈានទៅដល់ការគ្រប់គ្រង និងការរក្សាបាននូវប្រភពធនធានទឹកឱ្យរួចផុតពីការបំពុល រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយដូចតទៅ ៖

១- កំណត់ទីតាំងប្រភពទឹក និងបរិមាណទឹកសំរាប់បំរើដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម-សិប្បកម្ម និងសេវាកម្ម ។

២- គ្រប់គ្រងធនធានទឹកដើម្បីធានាថា ឧស្សាហកម្ម-សិប្បកម្ម និងសេវាកម្ម មានលទ្ធភាពទទួលនូវបរិមាណទឹកដែលមានគុណភាពសមស្របទៅតាមតំរូវការ ។

៣- តំរូវឱ្យមានការសាងសង់ប្រព័ន្ធប្រព្រឹត្តិកម្មសំអាតទឹកសំណល់ នៅតាមតំបន់អភិវឌ្ឍន៍វិស័យឧស្សាហកម្ម- សិប្បកម្ម និងសេវាកម្ម ដើម្បីកាត់បន្ថយនូវសារធាតុពុលទៅលើធនធានទឹក ។

៤- ជំរុញលើកទឹកចិត្តដល់ការអភិវឌ្ឍបច្ចេកវិជ្ជាថ្មីៗ សំរាប់ការផ្គត់ផ្គង់ទឹក គ្រប់គ្រងទឹកសំណល់ រួមមានការរក្សាទឹកភ្លៀងទុក វិធីសាស្ត្រក្នុងការប្រើប្រាស់ទឹកឡើងវិញ វិធីសាស្ត្រក្នុងការកែច្នៃទឹកសំណល់ និងការធ្វើប្រព្រឹត្តិកម្មសំអាតទឹកសំណល់ក្នុងរោងចក្រ ។

៥- កាត់បន្ថយឱ្យបានជាអតិបរមា នូវផលប៉ះពាល់ទៅលើគុណភាពទឹក ដោយដាក់ចេញនូវវិធានការនានាដូចជា ការកំណត់ស្តង់ដារគុណភាពទឹក បញ្ញត្តិស្តីពីការគ្រប់គ្រងទឹកសំណល់ និងទឹកភ្លៀង ការចេញអាជ្ញាប័ណ្ណទឹក និងអាជ្ញាប័ណ្ណបញ្ចេញទឹកសំណល់ ។

### ៤.២.៤. ទឹកសំរាប់ការប្រើប្រាស់ប្រចាំថ្ងៃ

ការបង្កើនលទ្ធភាពផ្គត់ផ្គង់ទឹកស្អាត និងអនាម័យសាធារណៈ គឺជាគោលដៅមួយនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា ។

ការផ្គត់ផ្គង់ទឹកស្អាតតំរូវឱ្យមានប្រភពទឹកគ្រប់គ្រាន់ មានគុណភាពល្អ និងទាមទារឱ្យមានការធ្វើប្រព្រឹត្តិកម្មសំអាតទឹកតាមលក្ខណៈបច្ចេកទេស ។

បច្ចុប្បន្ននេះ ការផ្គត់ផ្គង់ទឹកស្អាតពុំទាន់ធានាបានទៅតាមតម្រូវការជាក់ស្តែងនៅឡើយទេ ដោយបណ្តាញផ្គត់ផ្គង់ទឹកស្អាតមានលក្ខណៈចាស់ទ្រុឌទ្រោម និងទាមទារឱ្យមានការកែលំអនូវប្រសិទ្ធភាពនៃការផ្គត់ផ្គង់ទឹកជាបន្ទាន់។ ជាក់ស្តែង ការផ្គត់ផ្គង់ទឹកស្អាតតាមបណ្តាញនេះ បានប្រព្រឹត្តទៅតែនៅតាមទីក្រុង និងទីប្រជុំជនសំខាន់ៗប៉ុណ្ណោះ ចំណែកឯការផ្គត់ផ្គង់ទឹកស្អាតនៅតាមជនបទវិញគឺប្រព្រឹត្តទៅដោយប្រើប្រាស់អណ្តូងទឹក ស្រះ និងត្រពាំង។ល។ ដែលពុំទាន់មានការត្រួតពិនិត្យគុណភាពទឹកឱ្យបានច្បាស់លាស់ ជាហេតុធ្វើឱ្យប៉ះពាល់ដល់សុខុមាលភាពសាធារណៈ។

ដើម្បីដោះស្រាយបាននូវរាល់បញ្ហាខាងលើ និងដើម្បីធានាបាននូវការផ្គត់ផ្គង់សេវាកម្មទឹកគ្រប់គ្រាន់ រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយដូចតទៅ ៖

១- បន្តយកចិត្តទុកដាក់ក្នុងការគ្រប់គ្រង និងបង្កើនការផ្គត់ផ្គង់ទឹក ដោយផ្តល់អាទិភាពជាចំបងទៅលើតម្រូវការនៃការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋគ្រប់រូប នូវគុណភាព និងសុវត្ថិភាពគ្រប់គ្រាន់ ។

២- បន្តពង្រឹងពង្រីកបន្ថែមនូវការផ្គត់ផ្គង់ទឹកស្អាតនៅតាមទីក្រុង ទីប្រជុំជន និងជនបទ។

៣- បន្តលើកទឹកចិត្តដល់ការចូលរួមរបស់អ្នកវិនិយោគឯកជនក្នុងការស្តារ និងការអភិវឌ្ឍនូវការផ្គត់ផ្គង់ទឹកស្អាត ទាំងនៅទីក្រុង ទាំងនៅជនបទ ។

៤- បន្តជំរុញការអប់រំ និងផ្សព្វផ្សាយដល់សាធារណៈជន អំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ទឹកស្អាត ជាពិសេសប្រជាជនដែលរស់នៅតាមតំបន់ជនបទ ។

៥- បន្តជំរុញដល់ការសាងសង់ និងស្តារឡើងវិញនូវប្រព័ន្ធលូដោះទឹកសំណល់នៅតាមទីក្រុង និងនៅតាមតំបន់ទីប្រជុំជននានា ដោយតភ្ជាប់ទៅនឹងប្រព័ន្ធប្រព្រឹត្តិកម្មសំអាតទឹកសំណល់ដែលអាចជួយកាត់បន្ថយការបំពុលដល់ប្រភពធនធានទឹក ។

៦- បន្តជំរុញលើកទឹកចិត្ត ដល់ការអភិវឌ្ឍ ព្រមទាំងការស្រាវជ្រាវបច្ចេកវិទ្យាទឹក ដែលមានតំលៃទាបឱ្យសមស្របទៅតាមស្ថានភាពជាក់ស្តែងនៅកម្ពុជា ជាពិសេសសំរាប់ការប្រើប្រាស់របស់ប្រជាជននៅតាមតំបន់ជនបទ ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងការផ្គត់ផ្គង់ទឹកស្អាត ។

### ៤.២.៥. ទឹកសំរាប់នាវាចរ និងទេសចរណ៍

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយដែលសម្បូរទៅដោយប្រព័ន្ធផ្លូវទឹកដ៏ធំទូលាយ ជាពិសេសនៅតំបន់ទំនាបកណ្តាលនៃផ្ទៃប្រទេសដែលអាចផ្តល់លទ្ធភាពយ៉ាងល្អប្រសើរ ក្នុងការធ្វើនាវាចរបានស្ទើរពេញមួយឆ្នាំ។

ការធ្វើនាវាចរតាមផ្លូវទឹក ជាមធ្យោបាយមួយដែលមានតំលៃថោក ក្នុងការដឹកជញ្ជូនអ្នកដំណើរ និងទំនិញគ្រប់ប្រភេទទៅកាន់តំបន់ទីឆ្ងាយ ។

នាពេលបច្ចុប្បន្នដោយសារកត្តាធម្មជាតិប្រែប្រួលធ្វើអោយទន្លេ ស្ទឹង បឹងបួរ មួយចំនួនមានការផ្លាស់ប្តូរនូវរបបជលសាស្ត្រ និងទ្រង់ទ្រាយ ហើយជាពិសេសការរងកករនៃដីដែលធ្វើឱ្យរាំងដល់ការដឹកជញ្ជូនទំនិញ និងការធ្វើដំណើរ ទេសចរណ៍តាមផ្លូវទឹក ។ករណីខាងលើក៏អាចបណ្តាលឱ្យមានការប្រែប្រួលនូវរបបជលសាស្ត្រ និងទ្រង់ទ្រាយរបស់សមុទ្រផងដែរ ។ ទន្ទឹមនឹងនេះ ការអភិវឌ្ឍការងារទន្លេ ការគ្រប់គ្រងទិន្នន័យ និងពត៌មានស្តីពីឧតុនិយម និងរបបជលសាស្ត្រ ព្រមទាំងឪកាសសំរាប់ធ្វើការសិក្សានៅមានកំរិតនៅឡើយ ។

ដើម្បីដោះស្រាយបាននូវរាល់បញ្ហាខាងលើ និងធានាដល់ការដឹកជញ្ជូន និងការធ្វើដំណើរទេសចរណ៍តាមផ្លូវទឹកប្រកបដោយប្រសិទ្ធភាព រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយដូចតទៅ ៖

១- បន្តជំរុញដល់ការប្រើប្រាស់ផ្លូវទឹក ទាំងផ្លូវទឹកធម្មជាតិ ទាំងផ្លូវទឹកសិប្បនិមិត្ត សំរាប់ការដឹកជញ្ជូនទំនិញ អ្នកដំណើរ ទេសចរណ៍ និងការធ្វើដំណើរកំសាន្ត ។

២- បន្តយកចិត្តទុកដាក់ និងគិតគូរដល់ការគ្រប់គ្រងធារទឹក ព្រមទាំងកំរិតកំពស់ទឹកនៅក្នុងទន្លេ ស្ទឹង បឹងបួរ ប្រឡាយ និងសមុទ្រ សំរាប់បំរើឱ្យវិស័យនាវាចរ និងទេសចរណ៍ ។ រាល់គំរោងការងារអភិវឌ្ឍវិស័យធនធានទឹកសំរាប់រយៈពេលខ្លី មធ្យម និងវែង ត្រូវសិក្សាពិចារណាដល់ការប្រើប្រាស់សំរាប់វិស័យនាវាចរ និងទេសចរណ៍ ។

៣- បន្តជំរុញដល់ការបូមស្តារឡើងវិញនូវទីតាំងសំខាន់ៗព្រមទាំងការពារ និងអភិរក្សនូវប្រភពទឹក និងប្រព័ន្ធផ្លូវទឹកធម្មជាតិសំខាន់នានាដែលបំរើឱ្យដល់វិស័យនាវាចរ និងទេសចរណ៍ ។

### ៤.២.៦. ប្រសិទ្ធភាពនៃការប្រើប្រាស់ទឹក និងភាពខ្វះខាត

កន្លងមកប្រសិទ្ធភាពនៃការគ្រប់គ្រង និងការប្រើប្រាស់ទឹកនៅកម្ពុជាបានជួបប្រទះនូវការលំបាកដោយសារស្ថាប័នពាក់ព័ន្ធនឹងទឹកមួយចំនួនមានការទទួលខុសត្រូវដោយឡែកៗពីគ្នា ហើយការសហការគ្នានៅមានកំរិត ។ ម្យ៉ាងទៀត ការគ្រប់គ្រង និងការប្រើប្រាស់ទឹកពុំទាន់មានច្បាប់ជាមូលដ្ឋានគ្រប់គ្រាន់ក្នុងការអនុវត្ត និងការត្រួតពិនិត្យ ព្រមទាំងយន្តការនានាក្នុងការផ្សព្វផ្សាយ និងរៀបចំបង្កើតឱ្យមានការចូលរួមពីអ្នកវិនិយោគឯកជន អ្នកពាក់ព័ន្ធ អ្នកទទួលផល និងអង្គការអន្តរជាតិនានាក្នុងការប្រើប្រាស់ទឹកក៏ពុំទាន់មាននៅឡើយ ។

ប៉ុន្តែនាពេលដ៏ខ្លីខាងមុខនេះ ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជានឹងត្រូវបានពិនិត្យ និងអនុម័តដោយស្ថាប័ននីតិបញ្ញត្តិ ។ បន្ទាប់ពីច្បាប់នេះត្រូវបានប្រកាសឱ្យប្រើប្រាស់ជាផ្លូវការ ការគ្រប់គ្រងធនធានទឹក ការបែងចែកទឹក និងការអភិវឌ្ឍធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជានឹងប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាពដោយមានក្រសួងធនធានទឹក និងឧតុនិយមជាស្ថាប័នទទួលខុសត្រូវរួមលើការអនុវត្តច្បាប់ ។

ដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការគ្រប់គ្រងទឹកទទួលបានជោគជ័យ រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយដូចតទៅ ៖

១- ជំរុញឱ្យមានកិច្ចសហការល្អប្រសើររវាងស្ថាប័ននៃរាជរដ្ឋាភិបាល អ្នកវិនិយោគឯកជន អ្នកពាក់ព័ន្ធ និងអ្នកទទួលផលលើសកម្មភាព និងកម្មវិធីនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងលើការវិនិយោគ ការធ្វើអាជីវកម្ម និងការអភិវឌ្ឍធនធានទឹក ។

២- ជំរុញ និងលើកទឹកចិត្តដល់ការចូលរួមពីអ្នកវិនិយោគឯកជន អ្នកពាក់ព័ន្ធ អ្នកទទួលផល និងអង្គការអន្តរជាតិនានា ជាពិសេសការចូលរួមរបស់ស្ត្រីក្នុងការគ្រប់គ្រង ការធ្វើអាជីវកម្ម ការការពារ និងការអភិវឌ្ឍធនធានទឹក ។

៣- ធានា និងជំរុញដល់ការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក និងច្បាប់ពាក់ព័ន្ធនឹងទឹកដទៃទៀត ដើម្បីឆ្លើយតបទៅនឹងតំរូវការរបស់ជាតិគ្រប់ពេលវេលា ។

## ៤.៣. ការបែងចែក និងការចែកចាយទឹកប្រកបដោយសមធម៌

### ៤.៣.១. ការបែងចែក និងការចែកចាយទឹក

ទឹកមានសារៈសំខាន់បំផុតសំរាប់សុខុមាលភាព និងសកម្មភាពរបស់មនុស្សគ្រប់រូប ។ ដោយសារតែបរិមាណទឹកមានការប្រែប្រួលទៅតាមទឹកន្លែង និងទៅតាមពេលវេលាជាហេតុធ្វើឱ្យប្រជាពលរដ្ឋពុំមានលទ្ធភាពទទួលទឹកឱ្យបានស្មើភាពគ្នានៅឡើយ ។ ពិសេសជាងនេះទៅទៀតដោយសារតែធនធានហិរញ្ញវត្ថុមានភាពខុសគ្នា ប្រជាពលរដ្ឋពុំមានលទ្ធភាពដូចគ្នាក្នុងការប្រើប្រាស់ទឹក ។ តាមគោលការណ៍គ្រឹះជាមូលដ្ឋាន ប្រជាពលរដ្ឋគ្រប់រូបមានលទ្ធភាពទទួលទឹកគ្រប់គ្រាន់សំរាប់ជីវិត និងសុខភាព ។ ម្យ៉ាងទៀត មានការទទួលស្គាល់ជាលក្ខណៈអន្តរជាតិថា ទឹកគឺជាទំនិញសេដ្ឋកិច្ចមួយ និងគួរតែត្រូវបានបែងចែកក្នុងគោលបំណងបង្កើនឱ្យផលប្រយោជន៍សេដ្ឋកិច្ច នៅពេលដែលប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិជាមូលដ្ឋានក្នុងការទទួលទឹក ក៏ត្រូវមានកាតព្វកិច្ចដើម្បីធានាដល់ការប្រើប្រាស់ទឹករបស់ខ្លួនមិនមានឱ្យប៉ះពាល់ដល់សិទ្ធិប្រើប្រាស់ទឹករបស់អ្នកដទៃទៀត ។

ម្យ៉ាងទៀត ទឹកគឺជាមូលដ្ឋានគ្រឹះនៃតំរូវការសំរាប់ការអភិវឌ្ឍវិស័យកសិកម្ម ការផ្គត់ផ្គង់ទឹកស្អាត ឧស្សាហកម្ម-សិប្បកម្ម ថាមពលអគ្គិសនី នេសាទ វារីវប្បកម្ម នាវាចរ ទេសចរណ៍ ។ល។ ដែលស្ថាប័នមួយចំនួននៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រង និងប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាព និងសមធម៌ ។

បច្ចុប្បន្ននេះ ការបែងចែក និងការចែកចាយទឹកតាមវិស័យខាងលើពុំទាន់បានសមស្រប និងគ្រប់គ្រាន់ទៅតាមតំរូវការនៃការប្រើប្រាស់នៅឡើយ ។ យោងតាមហេតុផលប្រវត្តិសាស្ត្រ និងវប្បធម៌ ព្រមទាំងដោយសារបំណងចង់អោយសំរេចបាននូវសន្តិសុខស្បៀងជាតិនោះ ការស្រោចស្រពកសិកម្មតែងតែទទួលអាទិភាពក្នុងការចែកចាយទឹក ។ ក៏ប៉ុន្តែ ការប្រើប្រាស់ដទៃទៀត ក៏មានតំលៃសំរាប់សេដ្ឋកិច្ច និងសង្គមផងដែរដែលទាមទារឱ្យមានការបែងចែក និងការចែកចាយទឹកប្រកបដោយគតិបណ្ឌិតនាពេលអនាគត ដើម្បីសំរេចបាននូវអត្ថប្រយោជន៍ជាតិជាធំ ។

ម្យ៉ាងទៀតទិន្នន័យ និងពត៌មានស្តីពីតំរូវការទឹក ដែលវិស័យនិមួយៗបាននឹងកំពុងប្រើប្រាស់ក៏ពុំទាន់កំណត់បានច្បាស់លាស់ផងដែរ ។ ទន្ទឹមនឹងនេះ យន្តការ គោលការណ៍ និងបទដ្ឋានគតិយុត្តនានាក្នុងការកំណត់តំលៃប្រើប្រាស់ទឹកនៅមានកំរិតនៅឡើយ ។

ដើម្បីដោះស្រាយបាននូវរាល់បញ្ហាខាងលើ និងធានាបាននូវការបែងចែក និងការចែកចាយទឹកប្រកបដោយប្រសិទ្ធភាព និងសមធម៌ រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយដូចតទៅ ៖

១- ជំរុញការបែងចែក និងចែកចាយទឹកប្រកបដោយសមធម៌នៅក្នុងសង្គមជាតិកម្ពុជា ដោយរៀបចំបទបញ្ញត្តិ លិខិតបទដ្ឋាន និងនិតិវិធីចាំបាច់នានាដើម្បីធ្វើអោយសំរេចបាននូវការងារខាងលើនេះ ។ ការចែកចាយ និងបែងចែកទឹកនេះត្រូវទទួលស្គាល់ជាពិសេសនូវអត្ថប្រយោជន៍ក្នុងការផ្គត់ផ្គង់ទឹក អាហារ និងអនាម័យ ដែលស្ត្រីគ្រប់រូបមានតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រង និងការថែរក្សាក្នុងគ្រួសារ ។

២- ត្រូវកំណត់តំលៃ និងផ្តល់អាជ្ញាប័ណ្ណទឹកនៅទីកន្លែងណាដែលចាំបាច់អោយបានសមស្រប និងទាន់ពេលវេលា ។

៣- បែងចែកទឹកនៅក្នុងដំណាក់កាលខ្សត់ទឹក ទៅតាមលំដាប់អាទិភាពដូចជា:

- ការប្រើប្រាស់សំរាប់ហូបចុកនៅតាមទីប្រជុំជន
- ការប្រើប្រាស់សំរាប់ស្រោចស្រព
- ការប្រើប្រាស់សំរាប់វារីអគ្គិសនី
- ការប្រើប្រាស់សំរាប់ឧស្សាហកម្ម-សិប្បកម្ម និងសេវាកម្ម

- ការប្រើប្រាស់សំរាប់នាវាចរ
- ការប្រើប្រាស់សំរាប់វារីវប្បកម្ម
- ការប្រើប្រាស់សំរាប់គីរីតធារទឹកអប្បបរមា និងថែរក្សាប្រព័ន្ធអេកូឡូស៊ី ។

៤-ត្រូវយកចិត្តទុកដាក់យ៉ាងសកម្មលើកិច្ចព្រមព្រៀងអន្តរជាតិ ក្នុងការប្រើប្រាស់ និងការចែកចាយទឹក ជាពិសេសនៅក្នុងដំណាក់កាលខ្សត់ទឹកនៅតាមទន្លេ ស្ទឹង ព្រែក អូរដែលជាព្រំដែនជាមួយប្រទេសជិតខាង ។

## ៤.៣.២. ពត៌មាន និងចំណេះដឹងជាសាធារណៈ

កន្លងមក ក៏ដូចជាពេលបច្ចុប្បន្ននេះដែរ មូលដ្ឋានចំណេះដឹង និងការស្វែងយល់ជាសាធារណៈស្តីពីអត្ថប្រយោជន៍នៃទឹក និងផលវិបាកដែលបង្កឡើងដោយសារទឹកនៅមានកំរិតនៅឡើយ ។ម្យ៉ាងទៀតនៅតាមគ្រឹះស្ថានអប់រំ ការបញ្ចូលកម្មវិធីអប់រំពាក់ព័ន្ធនឹងទឹកក៏នៅមិនទាន់បានទូលំទូលាយ ។

ទន្ទឹមនឹងនេះ ការចូលរួមចំណែកលើការការពារ ការអភិរក្ស ការគ្រប់គ្រង និងការប្រើប្រាស់ទឹកក៏ពុំទាន់មានការគាំទ្រយ៉ាងសកម្មនៅឡើយពីអ្នកប្រើប្រាស់ក៏ដូចជាអ្នកពាក់ព័ន្ធដទៃទៀតផងដែរ ហើយទស្សនៈស្តីពីការចូលរួមវិភាគទាន និងការបង់ថ្លៃផ្គត់ផ្គង់សេវាកម្មទឹកនៅមានកំរិតនៅឡើយ ។

ដើម្បីដោះស្រាយបាននូវរាល់បញ្ហាខាងលើ និងបង្កើនការយល់ដឹងជាសាធារណៈ ស្តីពីអត្ថប្រយោជន៍នៃទឹក រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយដូចតទៅ ÷

១- បង្កើនការផ្សព្វផ្សាយ និងការណែនាំដល់សាធារណៈជន អំពីអត្ថប្រយោជន៍នៃទឹកចំពោះសុខុមាលភាពប្រជាជន និងការអភិវឌ្ឍសេដ្ឋកិច្ច ព្រមទាំងផ្សព្វផ្សាយនូវវិធីសាស្ត្រក្នុងការថែរក្សា ការអភិរក្ស ការគ្រប់គ្រង និងការប្រើប្រាស់ទឹកប្រកបដោយគុណភាព និងសុវត្ថិភាព ។
២- បង្កើនការគាំទ្រពីអ្នកប្រើប្រាស់ទឹក និងអ្នកពាក់ព័ន្ធនានាក្នុងការលើកដំកើងផលប្រយោជន៍សហគមន៍ និងផលប្រយោជន៍បុគ្គលលើការថែរក្សា ការអភិរក្ស ការគ្រប់គ្រង និងការប្រើប្រាស់ទឹក ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ។
៣- បញ្ចូលនូវពត៌មានស្តីពីធនធានទឹក និងតួនាទីរបស់ទឹកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមប្រកបដោយនិរន្តរភាពទៅក្នុងកម្មវិធីបណ្តុះបណ្តាលទូទៅនៅតាមគ្រឹះស្ថានអប់រំនានា ។
៤- បន្តការផ្សព្វផ្សាយដល់សាធារណៈជន ស្តីពីការចូលរួមបង់ថ្លៃផ្គត់ផ្គង់សេវាកម្មទឹកស្អាត ។
៥- ផ្សព្វផ្សាយ និងជំរុញដល់សមាជិកសហគមន៍កសិករប្រើប្រាស់ទឹក ឱ្យចូលរួមធ្វើការកសាងនូវមូលនិធិសំរាប់ការគ្រប់គ្រង និងការថែទាំប្រព័ន្ធធារាសាស្ត្រដើម្បីអោយមាននិរន្តរភាព ។

## ៤.៤. ការកាត់បន្ថយនូវគ្រោះមហន្តរាយដែលកើតឡើងពីទឹក

### ៤.៤.១. ទិដ្ឋភាពនៃការកាត់បន្ថយគ្រោះមហន្តរាយ

ដោយស្ថានភាពភូមិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតនៅផ្នែកខាងក្រោមនៃអាងទន្លេមេគង្គ និងទទួលរបបខ្យល់មូសុងនោះ បានធ្វើឱ្យប្រទេសកម្ពុជាប្រឈមមុខទៅនឹងគ្រោះមហន្តរាយបង្កឡើងពីមុខសញ្ញាគ្រោះថ្នាក់ដោយធម្មជាតិដែលបណ្តាលមកពីទឹក ដូចជាទឹកជំនន់ ព្យុះ និងគ្រោះរាំងស្ងួតជាបន្តបន្ទាប់ ។ ហេតុដូច្នេះហើយទើបអង្គការអន្តរជាតិ រួមទាំងគណៈកម្មការទន្លេមេគង្គ គណៈកម្មការព្យុះនៃគណៈកម្មការសេដ្ឋកិច្ច-សង្គមសំរាប់អាស៊ី និងប៉ាស៊ីហ្វិករបស់អង្គការឧតុនិយមពិភពលោក បានរៀបចំកម្មវិធី ឬគំរោងជាច្រើនសំរាប់កាត់បន្ថយនូវឥទ្ធិពលនៃគ្រោះមហន្តរាយទាំងនោះ ។

ជារៀងរាល់ឆ្នាំផ្ទៃដីមួយចំនួន លំនៅដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធសង្គម ទ្រព្យសម្បត្តិសាធារណៈត្រូវលិចលង់ និងខូចខាតដោយសារទឹកជំនន់ហើយប្រជាពលរដ្ឋមួយចំនួនបានរងគ្រោះរហូតដល់បាត់បង់ជីវិតទៀតផង ។ ដោយឡែកនៅរដូវប្រាំងវិញ តំបន់ភាគច្រើននៅក្នុងប្រទេសកម្ពុជាស្ទើរតែពុំមានទឹកគ្រប់គ្រាន់សំរាប់ប្រើប្រាស់ កន្លែងខ្លះមានទឹកដែរតែទឹកពុំមានគុណភាពសំរាប់ទទួលទានបានឡើយ ។ ព្រឹត្តិការណ៍បំពុលដោយចៃដន្យនៅផ្នែកខាងលើនៃទន្លេមេគង្គ មកលើប្រព័ន្ធទន្លេមេគង្គផ្នែកខាងក្រោមពុំទាន់មានផលប៉ះពាល់នៅឡើយ ។ ក៏ប៉ុន្តែការកើនឡើងនូវសកម្មភាពសេដ្ឋកិច្ច និងការកើនឡើងនូវការប្រើប្រាស់ទឹកនៅផ្នែកខាងលើនៃទន្លេមេគង្គនេះ បានបង្ហាញឱ្យឃើញពីគ្រោះមហន្តរាយនានា ដែលកើតឡើងពីព្រឹត្តិការណ៍ខាងលើ ។

នៅក្នុងព្រះរាជាណាចក្រកម្ពុជា គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយបានបង្កើតឡើងដើម្បីទទួលខុសត្រូវលើការងារគ្រប់គ្រងមុនពេល ក្នុងពេល និងក្រោយពេលមានវិបត្តិគ្រោះមហន្តរាយ ។ម្យ៉ាងទៀតការគំរាមកំហែងដោយគ្រោះមហន្តរាយបង្កឡើងដោយមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ ដែលមានសភាពធ្ងន់ធ្ងរនាពេលបច្ចុប្បន្ន នឹងអាចកាន់តែមានសភាពធ្ងន់ធ្ងរថែមទៀតនាពេលអនាគតក្នុងពេលដែលចំនួនប្រជាពលរដ្ឋ និងទ្រព្យសម្បត្តិជាតិមានការកើនឡើង ព្រមទាំងសេដ្ឋកិច្ចមានការអភិវឌ្ឍ ។

ដើម្បីដោះស្រាយបាននូវរាល់បញ្ហាខាងលើ និងធានាដល់កិច្ចការពារ និងការកាត់បន្ថយនូវការបាត់បង់អាយុជីវិត ទ្រព្យសម្បត្តិប្រជាពលរដ្ឋ ក៏ដូចជាទ្រព្យសម្បត្តិសាធារណៈពីគ្រោះមហន្តរាយបង្កឡើងដោយមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិ រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយដូចតទៅ ៖

១- ជំរុញ និងយកចិត្តទុកដាក់ដល់ការសិក្សា និងការសាងសង់ទំនប់ការពារទឹកជំនន់ ព្រមទាំងប្រឡាយដោះទឹកជំនន់ ក្នុងគោលបំណងកាត់បន្ថយអោយបានជាអតិបរមានូវគ្រោះមហន្តរាយធម្មជាតិដែលបណ្តាលមកពីទឹក ។

២- អនុវត្តន៍នូវវិធានការនានា ក្នុងការកាត់បន្ថយទឹកជំនន់នៅគ្រប់ទីកន្លែង ដែលផ្តល់នូវសក្តានុពលសេដ្ឋកិច្ចខ្ពស់ តាមរយៈការអប់រំសហគមន៍ ការផ្តល់ពត៌មានជាសាធារណៈ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ។

៣- ឆ្លើយតបជាបន្ទាន់នៅតំបន់ដែលទទួលរងគ្រោះដោយឥទ្ធិពលនៃភាពរាំងស្ងួត ទឹកជំនន់ និងមហន្តរាយដែលបង្កឡើងដោយទឹក ។

៤- បន្តលើកទឹកចិត្ត ព្រមទាំងជំរុញដល់ប្រជាពលរដ្ឋគ្រប់រូប និងគ្រប់ស្ថាប័នអោយចូលរួមលើវិធានការកាត់បន្ថយគ្រោះទឹកជំនន់តាមមធ្យោបាយនានាដូចជា ការរៀបចំទីទួលសុវត្ថិភាព ការផ្គត់ផ្គង់សំភារៈបរិក្ខារ គ្រឿងចក្រ ការសិក្សាអប់រំ ការបង្ហាញនូវបច្ចេកវិទ្យាថ្មីៗ សមស្របទៅតាមស្ថានភាពជាក់ស្តែង ។

៥- ចូលរួមយ៉ាងសកម្មក្នុងកម្មវិធីជាតិ អន្តរជាតិ និងតំបន់ ដើម្បីកាត់បន្ថយនូវផលប៉ះពាល់នៃគ្រោះមហន្តរាយដែលបង្កឡើងដោយទឹក ។

### ៤.៤.២. ការប្រមូលទិន្នន័យ ការព្យាករណ៍ និងការប្រកាសជូនដំណឹងជាមុន

រាល់វិធានការក្នុងការកាត់បន្ថយគ្រោះមហន្តរាយពាក់ព័ន្ធនឹងទឹក ត្រូវរៀបចំធ្វើការសិក្សា និងរៀបចំផែនការដោយផ្អែកលើទិន្នន័យ និងពត៌មានច្បាស់លាស់ ។ ការប្រកាសជូនដំណឹងជាមុនត្រូវឱ្យមានការព្យាករណ៍ជាក់លាក់អំពីលក្ខខ័ណ្ឌនាពេលអនាគត ។ ការព្យាករណ៍គ្រោះរាំងស្ងួត គ្រោះទឹកជំនន់នៅតាមទន្លេមេគង្គ ទន្លេបាសាក់ ទន្លេសាប ព្រមទាំងដៃរបស់វា និងការវិភាគបាតុភូតផ្សេងៗទៀតនៅក្នុងប្រទេសដើម្បីកាត់បន្ថយគ្រោះមហន្តរាយក៏នៅតែមិនទាន់ឆ្លើយតបនូវតំរូវការជាតិគឺទាមទារឱ្យមានមូលដ្ឋានទិន្នន័យ និងពត៌មានមួយដ៏ទូលំទូលាយ ។

ដើម្បីដោះស្រាយបាននូវរាល់បញ្ហាខាងលើ និងធានាធ្វើការព្យាករណ៍ប្រកបដោយប្រសិទ្ធភាព រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយដូចតទៅ ÷

១- បន្តពង្រឹងពង្រីកបន្ថែមទៀតនូវប្រព័ន្ធទិន្នន័យឧតុនិយម និងជលសាស្ត្រដែលជាមូលដ្ឋានបច្ចេកទេស និងតំរូវការចាំបាច់ដើម្បីទ្រទ្រង់ដល់ស្ទើរគ្រប់វិស័យដូចជា មហន្តរាយដែលកើតឡើងពីការប្រែប្រួលនៃអាកាសធាតុ ជំនន់ ការកំណត់ទីតាំងតំបន់លិចទឹក ការកំណត់ប្រេកង់ត្រូវ ។ល។ ដែលមានគ្រោះថ្នាក់ ។

២- ព្យាករណ៍រយៈពេលខ្លី មធ្យម វែង និងប្រកាសភាពអាសន្នជាមុន ដូចជា គ្រោះរាំងស្ងួត ទឹកជំនន់ ព្យុះ ។ល។ ដល់សាធារណៈជន និងស្ថាប័ននានាដែលពាក់ព័ន្ធ ។ ការព្យាករណ៍ ប្រកាសភាពអាសន្ននេះធ្វើឡើងសំរាប់ទូទាំងប្រទេស ចំពោះពត៌មានឧតុនិយម និងភាពរាំងស្ងួត ។ ដោយឡែក ពត៌មានជលសាស្ត្រធ្វើឡើងសំរាប់តែកន្លែងណាដែលអាចទទួលនូវភាពរងគ្រោះតែប៉ុណ្ណោះ ។

## ៤.៥. ការថែរក្សា ការការពារ និងនិរន្តរភាពនៃប្រព័ន្ធអេកូឡូស៊ី

ប្រទេសកម្ពុជាស្ថិតនៅទីតាំងដែលមានលក្ខណៈល្អប្រសើរនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ នាពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជានៅមានចំនួនប្រជាជនតិច ដែលពុំទាន់បង្កឱ្យមានសំពាធដ៏ធ្ងន់ធ្ងរមកលើមូលដ្ឋានធនធានធម្មជាតិនៅឡើយ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏មានភស្តុតាងជាច្រើនបង្ហាញពីការកើនឡើងនៃសំពាធមកលើធនធានទឹកដូចជា ការកាប់ព្រៃឈើ ការនេសាទត្រីដោយប្រើវិធីខុសច្បាប់ ការបង្ហូរទឹកសំណល់ចេញពីទីក្រុង និងទីប្រជុំជននានា ការចាក់សំណល់រឹង និងរាវ ការលេច និងការបង្ហូរប្រេងពីនាវា ចូលទៅក្នុងទន្លេ ស្ទឹង ព្រែក បឹងបួរ និងសមុទ្រ ។ ដូច្នេះត្រូវឱ្យចាត់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការទប់ស្កាត់នូវអំពើអសកម្មខាងលើនេះ ដូចដែលបណ្ដាប្រទេសក្នុងតំបន់ធ្លាប់ប្រើប្រាស់កន្លងមកក្នុងកិច្ចការពារ ធនធានទឹកឱ្យរួចផុតពីការខូចខាត និងការបំផ្លិចបំផ្លាញ ។

ដើម្បីដោះស្រាយបាននូវរាល់បញ្ហាខាងលើ និងធានាបាននូវបរិស្ថានបរិសុទ្ធ រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយដូចតទៅ ÷

១- ពង្រឹង ព្រមទាំងជំរុញការអនុវត្តច្បាប់ ស្ដីពីការគ្រប់គ្រងធនធានទឹក ច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ អនុក្រឹត្យ និងបទប្បញ្ញត្តិពាក់ព័ន្ធនានាដើម្បីត្រួតពិនិត្យនិងទប់ស្កាត់នូវរាល់គំរោងសាងសង់នានាដែលអាចធ្វើឱ្យប៉ះពាល់មកលើធនធានទឹកក៏ដូចជាប្រព័ន្ធអេកូឡូស៊ី ។

២- រៀបចំនីតិវិធីក្នុងការវាយតម្លៃ និងការកាត់បន្ថយផលប៉ះពាល់មកលើបរិស្ថាន និងសង្គម ហើយដាក់ឱ្យប្រើប្រាស់ ដោយស្ថាប័នរដ្ឋស្របគ្នាទៅនឹងនីតិវិធី ដែលអង្គការជាតិ និងអន្តរជាតិនានា កំពុងអនុវត្តយ៉ាងសកម្មនៅក្នុងប្រទេសកម្ពុជា ។

៣- រក្សាឱ្យបាននូវធារទឹកទន្លេ និងជីវិតកំពស់អប្បបរមាទឹកទន្លេ ស្ទឹង បឹងបួរ ព្រែក ដើម្បីធានាដល់ប្រព័ន្ធអេកូឡូស៊ី សង្គម វប្បធម៌ និង នាវាចរ ។

៤- វិភាគឱ្យបានគ្រប់ជ្រុងជ្រោយនូវរាល់គំរោងការអភិវឌ្ឍធនធានទឹក ដែលប៉ះពាល់ដល់ដំណើរផ្លាស់ប្តូរទឹកទន្លេរស់នៅរបស់ត្រី ។

៥- ហាមឃាត់ និងមានវិធានការជាបន្ទាន់ចំពោះការលុបបំពេញ ការជីក ឬការរំលោភលើផ្លូវទឹកទន្លេ ស្ទឹង បឹងបួរ ព្រែក ឬក៏ដីទំនាបដែលលិចទឹកជាប្រចាំ និងសមុទ្រដែលគ្មានច្បាប់អនុញ្ញាត អាចធ្វើឱ្យប៉ះពាល់មកលើធនធានទឹក ក៏ដូចជាប្រព័ន្ធអេកូឡូស៊ី និងបរិស្ថាន ។

៦- គ្រប់គ្រងច្រាំង និងតំបន់ដែលនៅជាប់ច្រាំងនៃទន្លេ និងស្ទឹងដើម្បីកុំឱ្យកើតមានឡើងនូវការហូរច្រោះដី ការចាក់ចោលនូវសំណល់សត្វពាហនៈ និងធាតុកខ្វក់ដទៃទៀត ការកាប់ព្រៃឈើ ការធ្វើអាជីវកម្មយករ៉ែ ដែលអាចធ្វើឱ្យប៉ះពាល់មកលើទឹកទន្លេ និងស្ទឹងទាំងនោះ ។

### ៤.៥.១. ក្របខ័ណ្ឌច្បាប់

កន្លងមកនៅក្នុងឯកសារច្បាប់ជាច្រើនដែលបានប្រកាសឱ្យប្រើប្រាស់មានចែងមិនទាន់គ្រប់គ្រាន់អំពីបញ្ហាដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹក ហើយការអនុវត្ត និងការត្រួតពិនិត្យការអនុវត្តច្បាប់ទាំងនោះក៏នៅមានកម្រិត ។

ដើម្បីដោះស្រាយបាននូវរាល់បញ្ហាខាងលើ និងឈានទៅអនុវត្តនី ព្រមទាំងត្រួតពិនិត្យច្បាប់ប្រកបដោយប្រសិទ្ធភាពខ្ពស់ រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយដូចតទៅ ÷

១- បន្តពង្រឹង និងបង្កើនសមត្ថភាពក្នុងការត្រួតពិនិត្យការអនុវត្តជាប្រចាំនូវច្បាប់ ស្តីពីការគ្រប់គ្រងធនធានទឹក និងច្បាប់នានាដែលពាក់ព័ន្ធនឹងទឹក ។

២- រៀបចំអនុក្រឹត្យ បទប្បញ្ញត្តិ លិខិតបទដ្ឋាន និងនីតិវិធីនានាដែលពាក់ព័ន្ធដល់ការគ្រប់គ្រង ការបែងចែក ការវិនិយោគ ការធ្វើអាជីវកម្ម ការថែរក្សា ការអភិរក្ស និងការអភិវឌ្ឍធនធានទឹកប្រកបដោយប្រសិទ្ធភាពខ្ពស់ និរន្តរភាព និងរក្សាបាននូវប្រព័ន្ធអេកូឡូស៊ី ។

### ៤.៥.២. ការពង្រឹងសមត្ថភាពស្ថាប័ន

នាពេលបច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជា បាន និងកំពុងយក ចិត្តទុកដាក់យ៉ាងខ្ពស់លើការពង្រឹង និងការកសាងសមត្ថភាពបន្ថែមដល់ស្ថាប័នពាក់ព័ន្ធនឹងទឹក ជាពិសេសក្រសួងធនធានទឹក និងឧតុនិយម ដើម្បីឱ្យក្រសួងនេះ អាចអនុវត្តតួនាទីរបស់ខ្លួនបាន ក្នុងការគ្រប់គ្រងធនធានទឹកឱ្យមានប្រសិទ្ធភាព និងនិរន្តរភាពខ្ពស់ ។ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានធ្វើការវិមជ្ឈការ និងផ្ទេរភារកិច្ចទទួលខុសត្រូវមួយចំនួនទៅឱ្យថ្នាក់មូលដ្ឋាន ដូចនេះទាមទារឱ្យមានការបណ្តុះបណ្តាលបន្ថែមទៀត នូវសមត្ថភាពដល់ថ្នាក់ក្រោមជាបន្តបន្ទាប់រហូតដល់ប្រជាពលរដ្ឋខ្មែរទាំងមូលតែម្តង ។

ដើម្បីដោះស្រាយបាននូវរាល់បញ្ហាខាងលើ និងបង្កើនសមត្ថភាពដល់មន្ត្រីគ្រប់លំដាប់ថ្នាក់ រាជរដ្ឋាភិបាលកម្ពុជា មានគោលនយោបាយដូចតទៅ ៖

១- បន្តពង្រឹងសមត្ថភាពមន្ត្រីថ្នាក់កណ្តាល ថ្នាក់ក្រោមបន្តបន្ទាប់ សហគមន៍ ប្រជាពលរដ្ឋគ្រប់លំដាប់ថ្នាក់ឱ្យយល់អំពីអត្ថប្រយោជន៍នៃទឹក ចំពោះជីវភាពរស់នៅប្រចាំថ្ងៃ និងការអភិវឌ្ឍសេដ្ឋកិច្ច ព្រមទាំងណែនាំឱ្យចូលរួមយ៉ាងសកម្មក្នុងការរៀបចំផែនការគ្រប់គ្រង ការថែរក្សា ការអភិរក្ស និងការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាពខ្ពស់ និរន្តរភាព និងរក្សាបាននូវប្រព័ន្ធអេកូឡូស៊ីតាមមធ្យោបាយនានា ដូចជារៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា បញ្ចូលក្នុងកម្មវិធីបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានសិក្សា ធ្វើការផ្សព្វផ្សាយតាមរយៈព្រឹត្តិប័ត្រពត៌មាន ទស្សនាវដ្តី បណ្តាញវិទ្យុ និងទូរទស្សន៍ ។ល។

២- បង្កើតគោលការណ៍ណែនាំក្នុងការចូលរួមរបស់សហគមន៍នៅក្នុងវិស័យទឹក ។

៣- ជំរុញ និងលើកស្ទួយដល់ស្ត្រី ឱ្យមានតួនាទីនៅក្នុងការគ្រប់គ្រងធនធានទឹក និងការផ្គត់ផ្គង់សេវាកម្មទឹក ។

៤- បង្កើនការណែនាំជាបន្តបន្ទាប់នូវបែបបទរដ្ឋបាល និងគ្រប់គ្រងតាមស្តង់ដាជាតិ និងអន្តរជាតិ ដល់ស្ថាប័ននានាដែលពាក់ព័ន្ធនឹងទឹក ។

៥- រៀបចំកញ្ចប់ថវិកាក្នុងការពង្រឹងសមត្ថភាពដល់មន្ត្រីនៅក្នុងស្ថាប័នវិស័យទឹក ទាំងនៅថ្នាក់កណ្តាល ទាំងនៅថ្នាក់មូលដ្ឋានបន្តបន្ទាប់ ។

### ៤.៥.៣. ផ្នែកហិរញ្ញវត្ថុ

និរន្តរភាពហិរញ្ញវត្ថុ គឺជាបញ្ហាសំខាន់មួយនៅក្នុងវិស័យនានានៃសេដ្ឋកិច្ចរួមមានទាំងវិស័យធនធានទឹកផងដែរ ។ការអភិវឌ្ឍ និងការគ្រប់គ្រងធនធានទឹកទាមទារនូវការវិនិយោគទុនដ៏ច្រើន ។ នាពេលបច្ចុប្បន្ននេះ ការផ្តល់ទុនវិនិយោគប្រចាំឆ្នាំលើការងារគ្រប់គ្រង និងអភិវឌ្ឍវិស័យធនធានទឹកនៅកម្ពុជានៅមានកំរិត ។ ពាក់ព័ន្ធដល់ថវិកាសំរាប់ទ្រទ្រង់ដល់ការស្តារ ការថែទាំ និងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព ប្រព័ន្ធព្យាករណ៍ឧតុនិយម និងជលសាស្ត្រក៏នៅមានកំរិត ។

បច្ចុប្បន្ននេះ ការអភិវឌ្ឍថាមពលវារីអគ្គិសនី និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅតាមទីក្រុង ទីរួមខេត្ត និងទីប្រជុំជននានាកំពុងតែមានការចាប់អារម្មណ៍ ព្រមទាំងបាននឹងកំពុងបណ្តាក់ទុនពីក្រុមអ្នកវិនិយោគឯកជនក្នុងស្រុក និងបរទេស និងភ្នាក់ងារផ្តល់ជំនួយនានា ។

ដើម្បីជំរុញ និងធានាបានក្នុងការដោះស្រាយនូវរាល់បញ្ហាខាងលើ រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយដូចតទៅ ៖

១- លើកទឹកចិត្ត និងបង្កលក្ខណៈងាយស្រួលដល់អ្នកវិនិយោគ សហគ្រាសឯកជន និងសហគមន៍ ក្នុងការចូលរួមលើការគ្រប់គ្រង និងអភិវឌ្ឍវិស័យធនធានទឹក ។

២- រៀបចំការផ្ទេរជាបណ្តើរៗនូវប្រព័ន្ធធារាសាស្ត្រ ឱ្យទៅសហគមន៍កសិករប្រើប្រាស់ទឹកដើម្បីគ្រប់គ្រង ប្រើប្រាស់ និងថែទាំដោយខ្លួនឯង ។

៣- ត្រួតពិនិត្យ និងកែសំរួលក្នុងករណីចាំបាច់លើការកំណត់ថ្លៃទឹកសំរាប់បំរើឱ្យការប្រើប្រាស់ និងការថែទាំប្រព័ន្ធធារាសាស្ត្រដោយសហគមន៍កសិករប្រើប្រាស់ទឹក ។

៤- ផ្ទេរប្រព័ន្ធផ្គត់ផ្គង់សេវាកម្មទឹកស្អាត ដែលនៅក្រោមការគ្រប់គ្រងរបស់រដ្ឋអោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់សហគ្រាសឯកជន តាមរយៈការជួល ការធ្វើកិច្ចសន្យាគ្រប់គ្រង ឬតាមរយៈរូបភាពផ្សេងទៀត ដែលធ្វើឡើងតាមនីតិវិធីជ្រើសរើសតាមលក្ខណៈប្រកួតប្រជែងសេរី ។

៥- ត្រួតពិនិត្យ និងកែសំរួលក្នុងករណីចាំបាច់លើការកំណត់តំលៃសេវាកម្មផ្គត់ផ្គង់ទឹកស្អាតដែលគ្រប់គ្រងដោយសហគ្រាស ឬក្រុមហ៊ុនឯកជន ។

៦- ត្រួតពិនិត្យ និងកែសំរួលក្នុងករណីចាំបាច់លើការកំណត់តំលៃសេវាកម្មផ្គត់ផ្គង់ថាមពលវារិអគ្គិសនី ដែលគ្រប់គ្រងដោយសហគ្រាស ឬក្រុមហ៊ុនឯកជន ។

៧- ទទួលខុសត្រូវលើការចំណាយថវិកាសំរាប់ការគ្រប់គ្រង និងការកាត់បន្ថយគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ។

៨- បន្តស្វែងរកជំនួយពីបរទេស និងបង្កើនកញ្ចប់ថវិកាជាតិ សំរាប់បំរើការងារគ្រប់គ្រង និងអភិវឌ្ឍវិស័យធនធានទឹក ។

## ៤.៦. ទិដ្ឋភាពជាលក្ខណៈអន្តរជាតិនៃទឹក

ផ្ទៃដីព្រះរាជាណាចក្រកម្ពុជា ប្រមាណ ៨៦% ស្ថិតនៅក្នុងអាងទន្លេមេគង្គ ។ តាមលក្ខណៈភូមិសាស្ត្រ គឺមានប្រទេសចិន ប្រទេសមីយ៉ាន់ម៉ា ប្រទេសឡាវ ប្រទេសថៃ និងមួយផ្នែកនៃប្រទេសវៀតណាមស្ថិតនៅផ្នែកខាងលើ និងមួយផ្នែកទៀតនៃប្រទេសវៀតណាមស្ថិតនៅផ្នែកខាងក្រោមនៃប្រទេសកម្ពុជា ។ ការកាត់បន្ថយទឹកជំនន់ ការថែរក្សាកំរិតធារទឹកអប្បបរមានៃទន្លេ និងគុណភាពទឹក ព្រមទាំងប្រព័ន្ធអេកូឡូស៊ីនៅកម្ពុជា មានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងបណ្តាប្រទេសខាងលើនេះ ។

ដើម្បីត្រៀមលក្ខណៈទប់ទល់នូវរាល់បញ្ហាខាងលើ ដែលនឹងអាចកើតមានឡើងនាពេលអនាគត រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយដូចតទៅ ÷

១- ចាត់វិធានការចាំបាច់ និងប្រើប្រាស់នូវរាល់មធ្យោបាយនានា ដើម្បីសហការឱ្យបានជិតស្និទ្ធជាមួយបណ្តាប្រទេស ដែលប្រើប្រាស់ទឹកបណ្តាទន្លេ ស្ទឹង ព្រែក បឹងបួរ និងធានាបាននូវការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ឱ្យមានការគោរពផលប្រយោជន៍គ្នាទៅវិញទៅមក ។

២- បន្តសហការយ៉ាងពេញទំហឹងជាមួយបណ្តាប្រទេសជិតខាង ដែលមានព្រំប្រទល់ជាប់នឹងកម្ពុជា ព្រមទាំងជាមួយនឹងប្រទេសក្នុងតំបន់ ដើម្បីសំរេចបាននូវគោលបំណងនៃកិច្ចព្រមព្រៀងឆ្នាំ ១៩៩៥ ស្តីពីកិច្ចសហប្រតិបត្តិការ ក្នុងការអភិវឌ្ឍអាងទន្លេមេគង្គប្រកបដោយនិរន្តរភាព ។

៣- បន្តធ្វើសមាហរណកម្មកម្ពុជាលើភាគអន្តរជាតិក្នុងវិស័យទឹក និងបន្តប្រើប្រាស់នូវរាល់កាលានុវត្តភាព ជាពិសេសតាមរយៈអង្គការអន្តរជាតិ និងធនាគារអភិវឌ្ឍន៍នានាដូចជា អង្គការសហប្រជាជាតិសំរាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ (UNESCO) អង្គការឧតុនិយមពិភពលោក (WMO) គណៈកម្មាធិការអភិវឌ្ឍន៍អាងទន្លេមេគង្គនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(ASEANMBDC) ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ធនាគារពិភពលោក (WB) មូលនិធិអន្តរជាតិសំរាប់ការអភិវឌ្ឍន៍កសិកម្ម (IFAD) មហាអនុតំបន់ទន្លេមេគង្គ (GMS) និងគណៈកម្មាការសេដ្ឋកិច្ច-សង្គមសំរាប់អាស៊ី និងប៉ាស៊ីហ្វិក (ESCAP) ដើម្បីជំរុញកិច្ចសហប្រតិបត្តិការ និងការយោគយល់ជាអន្តរជាតិក្នុងវិស័យទឹក ។

## ៤.៧. ការគ្រប់គ្រងធនធានទឹកនៅតាមបណ្តោយព្រំដែនកម្ពុជា ជាមួយប្រទេសជិតខាង

ស្ថានភាពភូមិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមួយដែលមានព្រំដែនគោកសម្បូរទៅដោយទន្លេ ស្ទឹង ព្រែកជីក អូរជាច្រើន តំណាងឱ្យប្រមាណ ២៦% នៃខ្សែព្រំដែន ដែលជារបាំងធម្មជាតិមួយ សំរួលដល់ការការពារសន្តិសុខនៃព្រំដែននោះហើយជាកត្តាវិជ្ជមានមួយជូនដល់ប្រជារាស្ត្រដែលតាំងលំនៅដ្ឋានតាមបណ្តោយផ្លូវទឹកទាំងនោះ មានប្រភពទឹកសំរាប់ប្រើប្រាស់ប្រចាំថ្ងៃ និងប្រកបអាជីវកម្មគ្រប់វិស័យ ។

យោងតាមសារៈសំខាន់នៃធនធានទឹក នៅតាមបណ្តោយព្រំដែនរវាងកម្ពុជា - ថៃ កម្ពុជា - វៀតណាម កម្ពុជា - ឡាវនោះ និងផ្អែកលើលទ្ធផលដែលរដ្ឋាភិបាល ( គណៈកម្មាធិការព្រំដែនជាតិ ) ទទួលបានក្នុងការចរចា កំណត់ខ័ណ្ឌព្រំសីមាព្រំដែនគោកជាមួយប្រទេសជិតខាងទាំងបី រាជរដ្ឋាភិបាលមានគោលនយោបាយដូចតទៅ ÷

១- ធានាការគ្រប់គ្រងមួយសមស្របតាមលក្ខណៈច្បាប់ និងការអនុវត្តជាអន្តរជាតិស្តីពីព្រំដែនដើរតាមខ្សែទឹក ដើម្បីកំណត់ព្រំដែនគ្រប់គ្រងរបស់កម្ពុជាតាមបណ្តោយព្រំដែនគោកនោះគឺ ៖

- ចំពោះកំណាត់ព្រំដែនទឹក ដែលមិនអាចធ្វើនាវាចរបាន ការគ្រប់គ្រងធនធានទឹកនៃព្រះរាជាណាចក្រកម្ពុជា មានព្រំប្រទល់ដល់ខ្សែដើរតាមបន្ទាត់ទ្រូងនៃខ្សែទឹកនោះ ។
- ចំពោះកំណាត់ខ្សែព្រំដែនទឹក ដែលអាចធ្វើនាវាចរបាន ការគ្រប់គ្រងធនធានទឹកនៃព្រះរាជាណាចក្រកម្ពុជា មានព្រំប្រទល់ដល់ខ្សែដើរតាមបន្ទាត់ទ្រូងនៃជ្រលងរឹកជ្រៅ ។

២- បន្តសហការយ៉ាងពេញលេញជាមួយបណ្តាប្រទេសជិតខាងទាំងបី ដែលមានព្រំប្រទល់ជាទន្លេស្ទឹង ព្រែក អូរ ជាប់ជាមួយកម្ពុជា ព្រមទាំងជាមួយនឹងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា គណៈកម្មាការទន្លេមេគង្គ ( MRC ) និងគណៈកម្មាធិការជាតិកិច្ចការព្រំដែនដើម្បីសំរេចបានទិសដៅ ដែលគោលនយោបាយនេះបានកំណត់យក ។

## ៤.៨. ការគ្រប់គ្រងទឹកតំបន់ឆ្នេរ និងទឹកសមុទ្រ

សព្វថ្ងៃនេះ បណ្តាខេត្តដែលនៅជាប់ឆ្នេរសមុទ្រ មានប្រជាជនរស់នៅតិចតួច ក៏ប៉ុន្តែនាពេលអនាគត ការអភិវឌ្ឍសេដ្ឋកិច្ចនឹងមានការរីកចំរើន ជាពិសេសការផលិតប្រេង និងឧស្ម័ននៅក្នុងសមុទ្រអាចមានផលប៉ះពាល់យ៉ាងខ្លាំងមកលើទឹកឆ្នេរ និងទឹកសមុទ្រ ។ ការប្រែប្រួលបរិស្ថានលើផែនដី បង្កើតឱ្យមានបាតុភូតធម្មជាតិនានាដូចជាការកើនឡើងនូវសីតុណ្ហភាពទឹក ឬការប្រែប្រួលនូវទឹកសមុទ្រ ដែលនឹងបង្កអោយមានផលប៉ះពាល់ដល់ធនធានទឹកឆ្នេរ និងទឹកសមុទ្រនៃប្រទេសកម្ពុជាផងដែរ ។ បច្ចុប្បន្ននេះនៅព្រះរាជាណាចក្រកម្ពុជា មានច្បាប់ គោលនយោបាយ និងបញ្ញត្តិមួយចំនួនទាក់ទងទៅនឹងដែនសមុទ្ររួចហើយ ប៉ុន្តែឯកសារនៅពុំទាន់គ្រប់គ្រាន់នៅឡើយ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តខិតខំការកសាងលិខិតបទដ្ឋាន និងឯកសារនានាថែមទៀតដើម្បីបញ្ជាក់អំពីការគ្រប់គ្រងទឹកឆ្នេរ និងទឹកសមុទ្រ ។

### ៤.៨.១. ក្របខ័ណ្ឌស្ថាប័ន និងក្របខ័ណ្ឌបញ្ញត្តិ

ទឹកឆ្នេរ និងទឹកសមុទ្រកម្ពុជា បានផ្តល់នូវអត្ថប្រយោជន៍យ៉ាងសំខាន់សំរាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមតាមរយៈការធ្វើវារីវប្បកម្ម និងទេសចរណ៍ ។ ដើម្បីធានាដល់ការអភិវឌ្ឍនេះ ឱ្យមាននិរន្តរភាព និងមិនធ្វើឱ្យខូចខាតដល់បរិស្ថាន គឺត្រូវឱ្យមានការប្រឹងប្រែងរួមគ្នាមួយ ។

កន្លងមក ការគ្រប់គ្រងការងារខាងលើមិនទាន់មានលក្ខណៈគ្រប់គ្រាន់ក្នុងការអនុវត្តនូវតួនាទីរបស់ខ្លួន តែប៉ុន្តែមានស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា និងអាជ្ញាធរខេត្តមួយចំនួនដែលទទួលខុសត្រូវដោយឡែកពីគ្នាស្តីពីទឹកឆ្នេរ ទឹកសមុទ្រ និងធនធានពាក់ព័ន្ធ ។ សព្វថ្ងៃនេះនៅពុំទាន់មានច្បាប់ដែលចែងឱ្យបានច្បាស់លាស់រវាងការគ្រប់គ្រងទឹកឆ្នេរ និងទឹកសមុទ្រ ជាមួយនឹងការគ្រប់គ្រងធនធាននៅតាមតំបន់ឆ្នេរ និងសមុទ្រ ដូចជារ៉ែនៅបាតសមុទ្រ ។

ដើម្បីជំរុញ និងធានាបានក្នុងការដោះស្រាយនូវរាល់បញ្ហាខាងលើ រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយដូចតទៅ ៖

១-ជំរុញដល់ការអភិវឌ្ឍទឹកឆ្នេរ និងទឹកសមុទ្រ ព្រមទាំងធនធានដែលពាក់ព័ន្ធផ្សេងទៀត ឱ្យមាននិរន្តរភាព និងទប់ស្កាត់ចំពោះរាល់សកម្មភាពណា ដែលគ្មាននិរន្តរភាព ។

២-រៀបចំច្បាប់សមស្របសំរាប់ការគ្រប់គ្រងទឹកឆ្នេរ និងទឹកសមុទ្រឱ្យមាននិរន្តរភាព ។

៣-សំរបសំរួលតាមរយៈគោលនយោបាយ ការរៀបចំផែនការ ក្របខ័ណ្ឌស្ថាប័ន និងក្របខ័ណ្ឌច្បាប់សមស្រប កិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពរវាងស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ និងសហគមន៍ក្នុងការគ្រប់ គ្រងទឹកឆ្នេរ ទឹកសមុទ្រ ព្រមទាំងធនធានផ្សេងៗទៀត ។

៤- ជំរុញ ដល់ការចូលរួមរបស់សហគមន៍ក្នុងការសំរេចចិត្ត លើផលប៉ះពាល់ទៅដល់បរិស្ថាន និងការរស់នៅ ។

៥-រាល់ស្ថាប័នជាតិ ផ្នែកឯកជន និងអង្គការក្រៅរដ្ឋាភិបាល ត្រូវមានធនធានគ្រប់គ្រាន់សំរាប់ការគ្រប់គ្រងទឹកឆ្នេរ ទឹកសមុទ្រ និងធនធានផ្សេងទៀត ។

## ៤.៨.២. ចំណេះដឹងខាងមូលដ្ឋាន

ចំណេះដឹងវិទ្យាសាស្ត្រស្តីពីទឹកឆ្នេរ ទឹកសមុទ្រ ប្រព័ន្ធអេកូឡូស៊ី ការនេសាទ ការទាញយកផលពីផ្កាថ្ម ខ្សាច់ ។ល។ ហើយកំរិត និងនិន្នាការនៃការប្រើប្រាស់របស់មនុស្សព្រមទាំងផលប៉ះពាល់នៃសកម្មភាពមនុស្សទៅលើឆ្នេរ និងបរិស្ថានសមុទ្រ សំរាប់ប្រទេសកម្ពុជា នៅមានកំរិតនៅឡើយ ។

ចំណេះដឹងជាប្រពៃណីរបស់សហគមន៍ដែលរស់នៅតាមតំបន់ឆ្នេរផ្តល់នូវធនធានពត៌មានដ៏មានតំលៃដែលអាចយកមកប្រើប្រាស់ឱ្យអស់លទ្ធភាព ។ ការអង្កេត និងការស្រាវជ្រាវ ត្រូវបានអនុវត្តដោយស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិជាច្រើន ។ តែប៉ុន្តែការងារទាំងនេះបានធ្វើឡើងដោយមានការសំរបសំរួលតិចតួច និងពុំមានផែនការជាយុទ្ធសាស្ត្រច្បាស់លាស់ ។

យន្តការសំរាប់ធានាដល់ការគ្រប់គ្រងធនធានឆ្នេរ និងសមុទ្រ គឺផ្អែកលើមូលដ្ឋានពត៌មានគ្រប់គ្រាន់ ក៏ប៉ុន្តែពត៌មានទាំងនេះនៅមានកំរិតនៅឡើយ ។

ដើម្បីជំរុញ និងធានាបានក្នុងការដោះស្រាយនូវរាល់បញ្ហាខាងលើ រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយដូចតទៅ ÷

១-ជំរុញ និងរៀបចំផែនការយុទ្ធសាស្រ្តសំរាប់ការអង្កេត និងការស្រាវជ្រាវ ដែលផ្តល់នូវចំណេះដឹងជាមូលដ្ឋាន សំរាប់ការគ្រប់គ្រងទឹកឆ្នេរ និងទឹកសមុទ្រព្រមទាំងប្រព័ន្ធអេកូឡូស៊ី និងធនធានសមុទ្រកម្ពុជាប្រកបដោយនិរន្តរភាព ។

២-ប្រើប្រាស់នូវចំណេះដឹងបែបប្រពៃណីរបស់សហគមន៍ ដែលរស់នៅតាមតំបន់ឆ្នេរសំរាប់ការគ្រប់គ្រងទឹកឆ្នេរ និងទឹកសមុទ្រព្រមទាំងប្រព័ន្ធអេកូឡូស៊ី និងធនធានសមុទ្រកម្ពុជា ។

៣-ជំរុញ និងសំរបសំរួលការផ្លាស់ប្តូរពត៌មាន និងចំណេះដឹងស្តីអំពីទឹកឆ្នេរ និងទឹកសមុទ្រព្រមទាំងប្រព័ន្ធអេកូឡូស៊ី និងធនធានសមុទ្រកម្ពុជា ជាមួយនឹងស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ និងអ្នកស្រាវជ្រាវ ។

៤-អប់រំសហគមន៍ស្តីអំពីការគ្រប់គ្រង និងអត្ថប្រយោជន៍នៃទឹកឆ្នេរ និងទឹកសមុទ្រ ។

### ៤.៨.៣. សកម្មភាពរបស់មនុស្សនៅតំបន់ឆ្នេរ និងទឹកឆ្នេរ

សកម្មភាពរបស់មនុស្សនៅតំបន់ឆ្នេរ និងនៅក្នុងអាងទន្លេ-ស្ទឹង បានធ្វើឱ្យមានសារធាតុបំពុល និងការរងកករទៅក្នុងតំបន់ឆ្នេរដែលអាចធ្វើឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើស្ថានភាពរបស់ទឹកឆ្នេរ ប្រព័ន្ធអេកូឡូស៊ី និងធនធានជីវសាស្រ្ត ។

ការកាប់ដើមកោងកាងយកទៅធ្វើធ្យូង ការធ្វើវារីវប្បកម្មខុសបែបបទបច្ចេកទេស ការផ្លាស់ប្តូរការប្រើប្រាស់ដី ដោយការធ្វើអាជីវកម្មព្រៃឈើ ការកាប់ព្រៃសំរាប់កសិកម្ម ទឹកកខ្វក់ដែលហូរមកពីផ្លូវនានា និងតំបន់ទីក្រុង សំណល់រាវបង្ហូរចេញពីគ្រឹះស្ថានសាធារណៈ និងឯកជន សំណល់រាវពីកប៉ាល់ក្បែរច្រាំង ការបំពុលឆ្នេរសមុទ្រដោយអ្នកទេសចរណ៍ អ្នកលក់ដូរ និងអ្នករស់នៅតាមតំបន់ឆ្នេរទាំងអស់នេះគឺជាសកម្មភាពរបស់មនុស្សដែលជះឥទ្ធិពលមិនល្អទៅលើឆ្នេរ ។ ទំនាក់ទំនងរវាងដីឆ្នេរ និងសមុទ្រ ត្រូវបានទទួលស្គាល់ជាគោលការណ៍នៃការគ្រប់គ្រងតំបន់ឆ្នេរចំរុះ ។ ការគ្រប់គ្រងទឹកឆ្នេរប្រកបដោយនិរន្តរភាពទាមទារឱ្យមានការគ្រប់គ្រងរាល់សកម្មភាពរបស់មនុស្ស ទាំងនៅលើដី ទាំងនៅតំបន់ឆ្នេរ ទាំងនៅក្នុងសមុទ្រ ។

ដើម្បីជំរុញ និងធានាបានក្នុងការដោះស្រាយនូវរាល់បញ្ហាខាងលើ រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយដូចតទៅ ÷

១- យកចិត្តទុកដាក់ពិចារណាដោយម៉ត់ចត់ និងកាត់បន្ថយជាអតិបរមានូវសក្តានុពលនៃផលប៉ះពាល់ទៅលើទឹកឆ្នេរ ដើម្បីឈានទៅធ្វើការគ្រប់គ្រងធនធានធម្មជាតិ និងគ្រប់គ្រងសកម្មភាពរបស់មនុស្សនៅក្នុងតំបន់អាងទន្លេ ដែលហូរផ្ទាល់ទៅកាន់ឈូងសមុទ្រថៃ ។

២- គ្រប់គ្រងធនធានធម្មជាតិ និងគ្រប់គ្រងសកម្មភាពរបស់មនុស្សនៅក្នុងតំបន់ឆ្នេរ តាមបណ្តោយឆ្នេរ តំបន់មាត់ពាម ទឹកឆ្នេរ និងតំបន់ឆ្នេរ ដែលទាក់ទងទៅនឹងរបបជលសាស្ត្រជាមួយនឹងតំបន់ឆ្នេរក្នុងមធ្យោបាយសមាហរណកម្មយ៉ាងពេញទំហឹងមួយ ដើម្បីជៀសវាងនូវការបង្កផលប៉ះពាល់ទៅលើតំបន់ឆ្នេរ ។

៣- គ្រប់គ្រងតំបន់ឆ្នេរឱ្យបានគ្រប់ជ្រុងជ្រោយលើការបំពុលដោយសារសំណល់រឹង និងរាវ ដែលអាចចូលទៅក្នុងតំបន់ទឹកឆ្នេរ ។

## ៤.៨.៤. ទឹកសមុទ្រ

ការប្រែប្រួលបរិស្ថានលើដែនដីដូចជា ការឡើងកំដៅនៃភពផែនដីអាចមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរថែមទៀតទៅលើដែនសមុទ្រ។ ការគ្រប់គ្រងនូវផលប៉ះពាល់ទាំងនេះប្រព្រឹត្តទៅបាន គឺត្រូវតែពឹងផ្អែកទៅលើកិច្ចព្រមព្រៀងអន្តរជាតិ និងសកម្មភាពអន្តរជាតិ ។

ការធ្វើនាវាចរ ការធ្វើអាជីវកម្មនេសាទ ការធ្វើអាជីវកម្មប្រេង និងឧស្ម័ន ការធ្វើអាជីវកម្មរ៉ែ ថ្មកំ ខ្សាច់ ។ល។ និងសកម្មភាពរបស់មនុស្សផ្សេងទៀតនៅក្នុងដែនសមុទ្រ ក៏នឹងអាចមានផលប៉ះពាល់ទៅលើបរិស្ថានសមុទ្រ ហើយការងារនេះត្រូវគ្រប់គ្រងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ការបង្កើតឡើងនូវតំបន់ហាមឃាត់ ត្រូវបានសហគមន៍អន្តរជាតិទទួលស្គាល់ជាយន្តការដ៏មានប្រសិទ្ធភាពសំរាប់កិច្ចការអភិរក្ស និងកែលំអដល់លក្ខណៈនៃធនធាននានាក្នុងសមុទ្រ ។

ដើម្បីជំរុញ និងធានាបានក្នុងការដោះស្រាយនូវរាល់បញ្ហាខាងលើ រាជរដ្ឋាភិបាលកម្ពុជាមានគោលនយោបាយដូចតទៅ ÷

១- សហការយ៉ាងពេញទំហឹងជាមួយបណ្តាប្រទេស ដែលស្ថិតនៅជុំវិញឈូងសមុទ្រថៃ ដើម្បីគ្រប់គ្រងឈូងសមុទ្រ និងធនធានសមុទ្រ ស្របតាមអត្ថប្រយោជន៍នៃអធិបតេយ្យភាពរបស់កម្ពុជា ។

២-គ្រប់គ្រងឱ្យគ្រប់ជ្រុងជ្រោយ នូវរាល់សំណល់រឹង រាវ ឧស្ម័ន និងសារធាតុជីវសាស្ត្រកខ្វក់ ដែលហូរចូលទៅក្នុងទឹកសមុទ្រ ។

៣-រៀបចំច្បាប់ បទប្បញ្ញត្តិ និងការគ្រប់គ្រងធនធានសមុទ្រ ដើម្បីកាត់បន្ថយឱ្យអស់ជាអតិបរមានូវផលប៉ះពាល់ផ្សេងៗ មកលើទឹកសមុទ្រ និងធនធានពាក់ព័ន្ធ ព្រមទាំងប្រព័ន្ធអេកូឡូស៊ី ។

៤- រៀបចំអភិរក្សតំបន់ទឹកឆ្នេរ ទឹកសមុទ្រ និងធនធានដែលពាក់ព័ន្ធ ព្រមទាំងប្រព័ន្ធអេកូឡូស៊ី ដែលកំពុងត្រូវបានគំរាមកំហែងពីធម្មជាតិ និងសកម្មភាពរបស់មនុស្ស ។

## ៥. ការអនុវត្តគោលនយោបាយ

គោលនយោបាយជាតិលើវិស័យធនធានទឹក នឹងត្រូវបានអនុវត្តដោយអ្នកប្រើប្រាស់ទឹក ស្ថាប័ននានានៃរាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងអ្នកពាក់ព័ន្ធទាំងឡាយក្នុងការអនុវត្តនូវរាល់សកម្មភាពដើម្បីសំរេចបានយ៉ាងពេញលេញនូវគោលបំណងនៃគោលនយោបាយនេះ។ ស្ថាប័ននានានៃរាជរដ្ឋាភិបាលកម្ពុជា នឹងទទួលខុសត្រូវលើការអនុវត្តគោលនយោបាយតាមផ្នែក និងសកម្មភាពនានាឱ្យមានលក្ខណៈស្របគ្នាជាមួយ និងគោលនយោបាយជាតិ ។ ក្រសួងធនធានទឹក និងឧតុនិយម និងស្ថាប័ននានានៃរាជរដ្ឋាភិបាលកម្ពុជា នឹងរៀបចំបញ្ចូលនូវយុទ្ធសាស្ត្រ និងសកម្មភាពនានាទៅក្នុងផែនការយុទ្ធសាស្ត្រ និងផែនការប្រចាំឆ្នាំ ចាំបាច់ជួយដល់ការរំលែកភារៈកិច្ចទទួលខុសត្រូវស្របតាមគោលនយោបាយនេះ។ ដោយឡែកក្រសួងធនធានទឹក និងឧតុនិយមមានភារៈកិច្ចទទួលខុសត្រូវលើការត្រួតពិនិត្យនូវរាល់សកម្មភាពនានាពាក់ព័ន្ធនឹងធនធានទឹក ព្រមទាំងមានភារកិច្ចក្នុងការចាត់វិធានការជាបន្ទាន់លើរាល់សកម្មភាពនានា ដែលពុំអាចធ្វើឱ្យសំរេចបាននូវគោលបំណងនៃគោលនយោបាយនេះ ។

ក្រសួង និងស្ថាប័ននានានៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវជូនដំណឹងដល់មន្ត្រីថ្នាក់កណ្តាល និងថ្នាក់ខេត្តស្តីពីគោលនយោបាយ ដោយធ្វើការពន្យល់នូវចំណុចនានាដែលមានផលប៉ះពាល់ដល់សកម្មភាពការងារ ។មន្ត្រីថ្នាក់ខេត្តនឹងទទួលខុសត្រូវលើការផ្សព្វផ្សាយនូវគោលនយោបាយនេះទៅដល់មន្ត្រីទូទៅ និងប្រជាពលរដ្ឋថ្នាក់ស្រុក ឃុំ និងភូមិ ព្រមទាំងពន្យល់នូវចំណុចនានា ដែលមានផលប៉ះពាល់ដល់អ្នកប្រើប្រាស់ទឹក។ ក្រសួងធនធានទឹក និងឧតុនិយម ត្រូវផ្សព្វផ្សាយផងដែរនូវគោលនយោបាយនេះដល់អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិនានា ព្រមទាំងធ្វើការពន្យល់នូវភាពទំនាក់ទំនងគ្នានៃគោលនយោបាយនេះក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានទឹក ។

ក្រសួងធនធានទឹក និងឧតុនិយម ត្រូវតាមដានពិនិត្យលើការអនុវត្តគោលនយោបាយនេះ ស្របពេលជាមួយនឹងការរៀបចំផែនការអភិវឌ្ឍសេដ្ឋកិច្ច - សង្គមរបស់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងលើកសំណើសុំទៅរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើការកែប្រែក្នុងករណីចាំបាច់ ។

## ៦. សេចក្តីសន្និដ្ឋាន

គោលនយោបាយជាតិលើវិស័យធនធានទឹកនេះសង្ឃឹមថានឹងមានការចូលរួមយ៉ាងសកម្ម គាំទ្រ និងអនុវត្ត ពីសំណាក់ស្ថាប័នពាក់ព័ន្ធ ផ្នែកឯកជន និងសាធារណៈក្នុងការបែងចែកទឹក ការគ្រប់គ្រងទឹក និងការអភិវឌ្ឍធនធានទឹកប្រកបដោយសមធម៌ ប្រសិទ្ធភាពខ្ពស់ និងនិរន្តរភាព សំរាប់ពេលបច្ចុប្បន្ន ក៏ដូចជាពេលអនាគត ។

គោលនយោបាយនេះ នឹងជួយកែលំអ ព្រមទាំងលើកកំពស់ជីវភាពប្រជាពលរដ្ឋឱ្យបានល្អប្រសើរ នឹងដើម្បីឈានទៅសំរេចបាននូវគោលដៅជាតិ ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា ព្រមទាំងជួយធ្វើឱ្យស្ថាប័ននៃរាជរដ្ឋាភិបាល និងប្រជាពលរដ្ឋគ្រប់លំដាប់ថ្នាក់បានយល់ដឹងច្បាស់អំពី អត្ថប្រយោជន៍នៃទឹក ដែលមានការពាក់ព័ន្ធយ៉ាងសំខាន់មិនអាចខ្វះបាន ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ព្រមទាំងចូលរួមយ៉ាងសកម្មលើការថែរក្សា ការអភិរក្ស ការគ្រប់គ្រង និងការប្រើប្រាស់ធនធានទឹកប្រកបដោយប្រសិទ្ធភាពខ្ពស់ និងនិរន្តរភាព ។